# ប្រជុំព្រះធម៌
# ក្នុងមហាសម័យ


រៀបរៀងដោយ

**ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន**



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ

ព.ស.២៥៥៦

ឆ្នាំ ២០១២

| | |
|---|---|
| ឈ្មោះសៀវភៅ | ប្រជុំព្រះធម៌ ក្នុងមហាសម័យ |
| រៀបរៀងដោយ | ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន |
| សហការី | លោកគ្រូ ហ៊ិត ណាហំ |
| | លោក សំ សុផល |
| | បុគ្គលិកពុទ្ធិកបណ្ឌិតសភា |
| ពិនិត្យដោយ | ក្រុមជំនុំពុទ្ធិកបណ្ឌិតសភា |
| ឯកសារ | សិក្សាស្រាវជ្រាវ |
| ការផ្សាយរបស់ | ពុទ្ធិកបណ្ឌិតសភា |
| | នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ |
| ចេញផ្សាយ | ព.ស.២៥៥៦ |
| | ខែធ្នូ ឆ្នាំ ២០១២ |

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# ឧទ្ទិសកថា

*សៀវភៅ "ប្រជុំព្រះធម៌ ក្នុងមហាសម័យ" នេះ ។ ខ្ញុំរៀបរៀងឡើង ដើម្បីជាការតបឧបការគុណដ៏ធំធេង មិនអាចគណនាបានរបស់លោកឪពុក ឈុន ឈាង អ្នកម្តាយ ហ៊ាន់ ឈារ៉ៃ ដែលជាអ្នកឲ្យកំណើតខ្ញុំក្នុងអត្តភាពនេះ ជាព្រះព្រហ្ម ជាបុព្វទេព ជាគ្រូបាអាចារ្យ ដែលបានផ្តល់នូវព្រហ្មវិហារធម៌ចំពោះខ្ញុំជាកូន ដែលអ្នកមានគុណទាំងពីរកំពុងមានជីវិតរស់នៅបច្ចុប្បន្ននេះ ក្នុងភូមិស្ទឹងរាង ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តកំពង់ចាម ។ ជាពិសេស លោកឪពុក អ្នកម្តាយបានផ្តល់នូវពូជសម្មាទិដ្ឋិដល់រូបខ្ញុំជាកូន ឲ្យមានឱកាសបានបួស ប្រព្រឹត្តនូវព្រហ្មចរិយធម៌ និងបានសិក្សាក្នុងព្រះពុទ្ធសាសនារហូតដល់បច្ចុប្បន្នកាលនេះ ។*

*កូនសូមផ្គងអញ្ជលីលើកហត្ថទាំងគូ ប្រណម្យជូនបុណ្យជាធម្មទាននេះ ដែលកូនបានរៀបរៀងនូវព្រះធម៌ ដែលមានសារៈសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ដែលជាព្រឹត្តិការណ៍ មានតែមួយគត់ក្នុងសម័យពុទ្ធកាលគឺមហាសម័យ ដែលមានព្រះធម៌ដ៏សំខាន់ ដែលព្រះអង្គទ្រង់សម្តែងក្នុងព្រៃមហាវ័ន ទុកជាបណ្ណាការជូនចំពោះលោកឪពុក អ្នកម្តាយទាំងពីរ ។*

*សូមអ្នកដ៏មានគុណទទួលត្រេកអរនូវធម្មទាននេះ សូមអនុមោទនា! ។*

*សូមធម្មទាននេះ បានជាគ្រឿងទ្រឧបត្ថម្ភដល់អ្នកដ៏មានគុណ បាននូវឧបនិស្ស័យ ឃើញច្បាស់នូវអរិយសច្ចធម៌ ដោយអរិយមគ្គ ក្នុងកាលដ៏សមគួរ និងបានជាបច្ច័យនៃសេចក្តីសុខគ្រប់យ៉ាង ក្នុងសង្សារវដ្ត ។*

**ពីកូន វ៉ាន់ ចាន់សារ៉ែន**

# មាតិកាអត្ថបទ


| មាតិកា | ទំព័រ |
|---|---|
| បុព្វហេតុនៃព្រះសូត្រ | (១) |
| អត្តទណ្ឌសូត្រ | ១ |
| មហាសមយសូត្រ | ៨ |
| សម្មាបរិព្វាជនីយសូត្រ | ៣៣ |
| កលហវិវាទសូត្រ | ៤១ |
| មហាវិយូហសូត្រ | ៥០ |
| ចូឡវិយូហសូត្រ | ៦១ |
| តុវដកសូត្រ | ៧១ |
| បុរាភេទសូត្រ | ៨០ |

## បុព្វហេតុនៃព្រះសូត្រ

មានរឿងប្រាកដច្បាស់ថា ក្នុងរវាងព្រំប្រទាល់ក្រុងកបិលពស្តុ និងក្រុងទេវទហៈ មានស្ទឹងមួយ ឈ្មោះថា **រោហិនី** ។ ស្ទឹងនេះតែងនាំមកទឹកសម្រាប់ធ្វើកសិកម្ម ដល់ប្រទេសទាំងពីរ ។ ពេលមួយក្នុងខែជេស្ឋ ស្រាប់តែមានទឹកតិច មិនអាចមានទឹកគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្មរបស់ប្រទេសទាំងពីរឡើយ ។ ទាំងពីរចំណែក ក៏បើកការប្រជុំពិភាក្សាគ្នា ពីបញ្ហាទឹក ដែលមិនមានគ្រប់គាន់ ។ ពួកអ្នកក្រុងកោលិយៈបានពោលសុំមុនផ្តាច់មុខថា ពួកយើង សុំយាំងទឹកទាំងនេះ សម្រាប់ស្រែរបស់ពួកយើង ព្រោះបើបែងចែកជាពីរចំណែក មិនអាចគ្រប់គ្រាន់បានឡើយ ។ ពួកក្រុងសក្យៈពោលជំទាស់ ព្រោះខ្លួនត្រូវការផ្តាច់មុខដែរ ។ ការប្រជុំគ្នា មិនមានយោបល់ណាមួយស្របគ្នានោះឡើយ ។ ការពោលពាក្យមិនពីរោះក៏កើតឡើង រហូតដល់ជេរដល់ពូជពង្សក្សត្រ ដែលជាបុព្វក្សត្រអ្នកបង្កើតវង្សក្នុងសក្យវង្ស និងកោលិយវង្ស ។ ការអត់ទ្រាំនឹងសំដីដែលបានជេរប្រហារនោះមិនបាន ក៏មានមនុស្សក្រោកឡើង វាយតប់គ្នា រហូតក្លាយជាជម្លោះដ៏ធំ ។

ពួកមនុស្សទាំងនោះ បាននាំយករឿងរ៉ាវទាំងអស់ ទៅក្រាបទូលព្រះមហាក្សត្ររបស់ខ្លួនរៀងៗ ខ្លួន ។ ពួកក្សត្រទាំងនោះ ក៏ផ្ទុះកំហឹងឡើង ព្រោះការដែលមានគេជេរដល់ពូជពង្សរបស់ខ្លួន ហើយក៏មានបំណងធ្វើចម្បាំងឡើង ដើម្បីបង្ហាញពីភាពអង្គអាចរបស់ខ្លួន ។ មហាទ័ពប្រកប

ដោយអង្គប្អូនយ៉ាងច្រើន បានចេញដំណើរឆ្ពោះទៅព្រំដែនទនាស្ទឹង រោហិនី ដើម្បីធ្វើសឹកសង្គ្រាម ។

ក្នុងកាលណោះ ព្រះពុទ្ធបរមគ្រូកំពូលឯក ព្រះអង្គគង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី[១] ។ ក្នុងវេលាជិតភ្លឺ ព្រះអង្គទ្រង់រមិលសត្វលោក ដោយករុណាសមាបត្តិ ។ ព្រះអង្គឃើញក្សត្រទាំងនោះហើយ ដោយសំណាញ់ញាណរបស់ព្រះអង្គ ។ ក្នុងបុព្វណ្ហសម័យ ព្រះអង្គទ្រង់យាងបិណ្ឌបាត បំពេញបុព្វកិច្ចជាធម្មតា រហូតដល់រសៀលព្រះអង្គយាងចេញពីព្រះគន្ធកុដិ មិនបានប្រាប់ដល់ភិក្ខុណាមួយឡើយ ហើយព្រះអង្គមកប្រាកដខាងលើស្ទឹងរោហិនី ។

ពេលនោះ មហាទ័ពទាំងពីរ ក៏មកដល់ស្ទឹងនោះដែរ ។ ស្រាប់តែផ្ទៃមេឃនោះទាំងមូល ងងឹតសូន្យឈឹងដោយពុទ្ធានុភាព ។ ការភ័យខ្លាច តក់ស្លុតក៏បានកើតឡើង ។ ពេលនោះ មានពន្លឺឆព្វណ្ណរង្សីផ្សាយចេញពីព្រះវរកាយនៃព្រះពុទ្ធ ប្រាកដច្បាស់ឡើង ។ ធ្វើឲ្យក្សត្រ និងមហាទ័ពទាំងនោះបានឃើញច្បាស់ប្រាកដថា ព្រះពុទ្ធជាអម្ចាស់ ព្រះអង្គទ្រង់គង់ព្រះភ្នែនព្វដ៏ខាងលើ ។ ពួកក្សត្រទាំងនោះ គិតដូចគ្នាថា យើងមិនអាចសម្លាប់បុគ្គលណាមួយ ក្នុងទីចំពោះព្រះភក្ត្រ ព្រះពុទ្ធជាម្ចាស់ឡើយ ហើយក៏នាំគ្នាបោះបង់សាស្ត្រាវុធចោល លុតជង្គង់ថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ ។ ព្រះអង្គទ្រង់យាងចុះពីព្វដ៏អាកាស មកគង់លើកម្រាលដែលគេក្រាលលើ

[១] ក្នុងខុទ្ទកនិកាយ ឯកកនិបាត សម្មោទមានជាតក ពោលថា ព្រះពុទ្ធជាម្ចាស់ គង់នៅក្នុងវត្តនិគ្រោធារាម ជិតក្រុងកបិលពស្តុ ។

ប្រាំងខ្សាច់ទៀបស្ទឹងរោហិនីនោះ ។

ព្រះសាស្តា ទោះបីព្រះអង្គជ្រាបហើយ ក៏នៅសាកសួរថា មហារាជទាំងឡាយ ពួកព្រះអង្គយាងមកទីនេះ ធ្វើអ្វី?

ពួកក្សត្រទាំងនោះឆ្លើយថា បពិត្រព្រះអង្គ ទូលព្រះបង្គំមកទីនេះ មិនមែនដើម្បីកម្សាន្តស្ទឹង ឬក៏មកលេងទឹកទេ ទូលព្រះបង្គំមកធ្វើសង្គ្រាម ។

(ព្រះពុទ្ធសួរ) ចុះរឿងដូចម្តេច បានជានាំគ្នាធ្វើសង្គ្រាម? ។

(ក្សត្រឆ្លើយ) បពិត្រព្រះអង្គ ព្រោះរឿងទឹក ។

(ព្រះពុទ្ធសួរ) មហារាជទាំងឡាយ ទឹកមានតម្លៃប៉ុន្មាន?

(ក្សត្រឆ្លើយ) បពិត្រព្រះអង្គ ទឹកមានតម្លៃតិចតួច ។

(ព្រះពុទ្ធសួរ) មហារាជទាំងឡាយ ផែនដីមានតម្លៃប៉ុន្មាន?

(ក្សត្រឆ្លើយ) បពិត្រព្រះអង្គ ផែនដីមានតម្លៃរាប់ប្រមាណមិនបាន ។

(ព្រះពុទ្ធសួរ) មហារាជទាំងឡាយ ក្សត្រមានតម្លៃប៉ុន្មាន?

(ក្សត្រឆ្លើយ) បពិត្រព្រះអង្គ ក្សត្រមានតម្លៃរាប់ប្រមាណមិនបាន ។

ព្រះពុទ្ធទ្រង់ត្រាស់ថា មហារាជទាំងឡាយ បើទឹកមានតម្លៃតិចតួច ហេតុដូចម្តេច ក៏ព្រះអង្គញ៉ាំងក្សត្រទាំងឡាយ ដែលមានតម្លៃរាប់ប្រមាណមិនបាន ឲ្យវិនាសទៅកើត ?

ទើបព្រះអង្គទ្រង់សម្តែងផន្ទនជាតក តេរសកនិបាត មានក្នុងបិដក លេខ ៥៩ ទំព័រ ២៧០ អំពីពៀររបស់ខ្លាឃ្មុំនិងដើមពន្រ ។ ព្រះពុទ្ធអង្គណែនាំពីទោសនៃការចងពៀរគ្នា ហើយព្រះអង្គពោលគាថាថា

> ឥច្ឆេវ ជន្តុនោ ឥស្សំ  ឥស្សោ ច បន ជន្តុនំ
> អញ្ញមញ្ញំ វិវាទេន  អញ្ញមញ្ញមឃាតយុំ ។

ដើមពន្រចងពៀរ និងខ្លាឃ្មុំ ឯខ្លាឃ្មុំចងពៀរនឹងដើមពន្រ ហើយបាន

សម្លាប់គ្នាទៅវិញទៅមក ដោយការទាស់ទែងគ្នាទៅវិញទៅមក ដោយប្រការដូច្នេះឯង ។

ឯវមេវ មនុស្សានំ វិវាទោ យត្ថ ជាយតិ
មយូរនច្ចំ នច្ចន្តិ យថា តេ ឥស្សជន្តុនា។

ខ្លាឃ្មុំ និងដើមពជ្រនោះ ចងពៀរវេរាយ៉ាងណា ការទាស់ទែងរបស់មនុស្សទាំងឡាយ កើតមានក្នុងទីណា មនុស្សទាំងនោះឈ្មោះថា ដូចជាក្ងោកពង់ ក្នុងទីនោះ ក៏យ៉ាងនោះដែរ ។

តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
សម្មោទថ មា វិវទថ មា ហោថ ឥស្សជន្តុនា។

តថាគតនឹងសំដែងនូវហេតុនោះ ថ្វាយមហារាជ ពួកមនុស្សដែលមកប្រជុំក្នុងទីនេះ មានចំនួនប៉ុន្មាន សូមសេចក្តីចម្រើនមានដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហាបពិត្រ ព្រមព្រៀងគ្នា កុំទាស់ទែងគ្នា កុំឲ្យដូចខ្លាឃ្មុំ និងដើមពជ្រឡើយ ។

សាមគ្គិមេវ សិក្ខេថ ពុទ្ធេហេតំ បសំសិតំ
សាមគ្គិរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ។

សូមមហាបពិត្រសិក្សានូវសេចក្តីព្រមព្រៀងគ្នាតែម៉្យាង ព្រោះសេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយសរសើរហើយ បុគ្គលអ្នកត្រេកអរ ក្នុងសេចក្តីព្រមព្រៀងគ្នា អ្នកតាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកព្រះនិព្វានជាទីក្សេម ចាកយោគៈទាំងឡាយឡើយ ។

បន្ទាប់ពីព្រះអង្គសម្តែងព្រះជាតកនេះរួចហើយ  ព្រះអង្គសម្តែងរឿងមួយទៀត  កុំឲ្យជឿដោយគ្រាន់តែឮតៗគ្នានោះ  ព្រះអង្គបាននាំមកនូវរឿងទុទ្ទុភាយជាតក មានក្នុងបិដកលេខ ៥៨ ទំព័រ ២០៩ ។ សេចក្តីសំខាន់ដែលព្រះអង្គសម្តែងជាគាថាថា

វេលុវំ បតិតំ សុត្វា  ទុទ្ទុភន្តិ សសោ ជវិ
សសស្ស វចនំ សុត្វា  សន្តត្តា មិគវាហិនី។

ទន្សាយឮស្គរផ្លែព្នៅជ្រុះថា ទុទ្ទុភ ដូច្នេះ ក៏ស្ទុះបោលប្រេច
ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត ។

អប្បត្វា បទវិញ្ញាណំ  បរឃោសានុសារិនោ
បនាទបរមា ពាលា  តេ ហោន្តិ បរបត្តិយា។

ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែកនៃសោតវិញ្ញាណ ឮសំឡេងនៃជនដទៃ  មានសេចក្តីប្រហែសធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ ។

យេ ច សីលេន សម្បន្នា  បញ្ញាយូបសមេ រតា
អារកា វិរតា ធីរា  ន ហោន្តិ បរបត្តិយា ។

ចំណែកពួកជនណា បរិបូណ៌ដោយសីលនិងបញ្ញា ត្រេកអរក្នុងការស្ងាប់រម្ងាប់ ជាធីរជន អ្នកឆ្ងាយ អ្នកវៀរចាកបាប ធីរជននោះ  មិនលុះតាមពាក្យជនដទៃទេ។

បន្ទាប់ពីរឿងសត្វទន្សាយមក  ព្រះពុទ្ធបរមគ្រូ  ទ្រង់សម្តែងនូវព្រះជាតក  ដែលជាប់ទាក់ទងនឹងការវិវាទ  ពៀរនឹងគ្នា  របស់សត្វចាបចៀប

កប្បាស ឈ្មោះ លដុកិកជាតក បិដកលេខ ៥៩ ទំព័រ ១០ ដើម្បីឲ្យពួកក្សត្រទាំងនោះ ឃើញទោសនៃការឈ្លោះទាស់ទែងគ្នា ហើយព្រះអង្គសម្តែងព្រះគាថាថា

កាកញ្ច បស្ស លដុកិកំ មណ្ឌូកំ នីលមក្ខិកំ
ឯតេ នាគំ អឃាតេសុំ បស្ស វេរស្ស វេរិនំ
តស្មា ហិ វេរំ ន កយិរាថ អប្បិយេនបិ កេនចិ ។

អ្នកចូរមើលនូវក្អែក ចាបចៀបកប្បាស កង្កែបនិងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល ( នូវគតិ ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើនូវពៀរ នឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ។

ក្នុងការស្តាប់ជាតកទាំងបីរឿងនេះ ពួកក្សត្រទាំងនោះ ក៏មានចិត្តទោរទន់ មិនមានការថ្នាំងថ្នាក់គ្នា មានមេត្តាចំពោះគ្នា នឹងគ្នា ។

ព្រះពុទ្ធដ៏មានព្រះភាគ ក៏បាននាំមកនូវរឿង ដែលជាគោលនៃការសាមគ្គីគ្នា ព្រមព្រៀងគ្នា ចំនួនពីររឿងមកទៀត ។ ព្រះអង្គបានសម្តែងនូវរុក្ខធម្មជាតក មានក្នុងបិដកលេខ ៥៨ ទំព័រ ៣២ ដោយព្រះគាថាបញ្ជាក់ថា

សាធូ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញជា
វាតោ វហតិ ឯកដ្ឋំ ព្រហន្តម្បិ វនប្បតឹ ។

មានពួកញាតិច្រើននាក់ប្រពៃហើយ សូម្បីពួកឈើ ដែលដុះក្នុងព្រៃ

ច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរំលំនូវឈើជាធំក្នុងព្រៃ បរិបូណ៌ ដោយមែកនឹងប្រគាប ដែលតាំងនៅតែឯង ។

បន្ទាប់មកព្រះអង្គសម្តែងពីរឿងក្រួចដែលសាមគ្គីគ្នា រមែងចម្រើន កាលណា វិវាទគ្នា ទាស់ទែងគ្នា រមែងវិនាស មានឈ្មោះថា សម្មោទមាន ជាតក មានក្នុងបិដកលេខ ៥៨ ទំព័រ ១៥ ហើយមានគាថាថា

សម្មោទមានា គច្ឆន្តិ ជាលមាទាយ បក្ខិនោ
យទា តេ វិវទិស្សន្តិ តទា ឯហិន្តិ មេ វសំ ។

ពួកបក្សីស្រុះស្រួលគ្នានាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះ ជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនេះ នឹងលុះក្នុង អំណាចអញក្នុងកាលនោះមិនខានឡើយ ។

កាលណា ព្រះពុទ្ធជាអម្ចាស់ត្រាស់សម្តែងជាតកទាំង ៥ រឿងនេះ ហើយ ព្រះអង្គបានសម្តែងនូវអត្តទណ្ឌសូត្រ ដែលមានសេចក្តីយ៉ាងពីរោះ ជក់ចិត្ត មានក្នុងខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៣១៣ ។ អត្តទណ្ឌសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានខែពង្រីកសេចក្តីយ៉ាង ពីរោះ មានក្នុងមហានិទ្ទេស បិដកលេខ ៦៦ ចាប់ពីទំព័រ ១២១ រហូតដល់ ទំព័រ ២១១ ។

មហាភជទាំងឡាយ ស្តាប់ព្រះធម្មទេសនាចប់កាលណា មាន សេចក្តីជ្រះថ្លា ហើយប្រឹក្សាគ្នាថា ប្រសិនបើ ព្រះពុទ្ធជាម្ចាស់ ព្រះអង្គមិន យាងមកទេ ពួកយើងនឹងសម្លាប់គ្នា នឹងគ្នា រហូតឈាមក្លាយជាទឹកក្នុង

ស៊ីងរោហិនីនេះមិនខាន។ ពួកយើងមានជីវិត ព្រោះអាស្រ័យព្រះសាស្តា បើព្រះសាស្តាគង់នៅគ្រប់គ្រងរាជ្យ រាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ ព្រមទាំងទ្វីបតូច ២,០០០ ជាបរិវារ នឹងនៅក្នុងកណ្តាប់ដៃព្រះអង្គ ។ ព្រះអង្គនឹងរាជឱរសរាប់ពាន់ នឹងមានពួកក្សត្រជារាជបរិវាររបស់ព្រះអង្គយ៉ាងច្រើនហែហម ។ តែព្រះអង្គលះបង់រាជសម្បត្តិ ហើយសាងបព្វជ្ជា រហូតដល់បានសម្រេចសម្មាសម្ពោធិញ្ញាណ ។ ឥឡូវនេះ ព្រះអង្គគួរមានពួកក្សត្រ ជាបរិវារដែរ ។ ទើបបានព្រមព្រៀងគ្នា ឲ្យរាជបុត្រ មួយខាងៗ ២៥០ ព្រះអង្គ បួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធ ហើយព្រះអង្គនាំចូលទៅគង់ក្នុងព្រៃមហាវ័ន នាដែនសក្កៈនោះឯង ។

ក្នុងបុព្វណ្ហសម័យ ព្រះអង្គមួយអន្លើដោយព្រះភិក្ខុសង្ឃចំនួន ៥០០ អង្គ និមន្តចូលទៅបិណ្ឌបាត ក្នុងទីក្រុងទាំងពីរ ។ ពេលខ្លះ ក្នុងក្រុងកបិលពស្ដុ ពេលខ្លះ ក្នុងក្រុងទេវទហៈ ។ ពួកភិក្ខុទាំង ៥០០ អង្គ កាលចូលទៅបិណ្ឌបាត ក៏ឃើញនូវរាជកុមារីដែលធ្លាប់ជាភរិយារបស់ខ្លួន ក៏មានចិត្តនឹកអាឡោះអាល័យ ហើយមានបំណងសឹកទៅជាគ្រហស្ថ ដើម្បីរួមរស់ជាមួយនឹងភរិយាវិញ ។ ព្រះពុទ្ធជាអម្ចាស់ទ្រង់ជ្រាបនូវភាពរវើរវាយនៃភិក្ខុទាំងឡាយ ទ្រង់ពិចារណាថា ធម្មកថាដូចម្តេចហ្ន៎ ជាទីសប្បាយនៃភិក្ខុទាំងឡាយនេះ ?។ ក៏ទ្រង់ជ្រាបថា កុណាលធម្មទេសនា ទើបជាទីសប្បាយនៃភិក្ខុទាំងឡាយ ។ ព្រះសាស្តាក៏នាំភិក្ខុទាំងនោះ ទៅកាន់ព្រៃហេមពាន្ត ហើយពណ៌នារឿងសកុណជាតក ដែលមានក្នុងបិដកលេខ ៦១ ទំព័រ១៥៤ នឹងសេចក្តីពិស្តារក្នុងអដ្ឋកថា កុណាលជាតក ។ ព្រះពុទ្ធជាអម្ចាស់

សម្តែងរឿងនេះចប់កាលណា ពួកភិក្ខុទាំង ៥០០ អង្គ ក៏បានសម្រេចនូវសោតាបត្តិផល ។ ពេលនោះ ឫទ្ធិក៏មានដល់ភិក្ខុទាំងនោះ ព្រមជាមួយសោតាបត្តិមគ្គ ។ លំដាប់នោះ ព្រះសាស្តា ក៏ហោះឡើងពីផ្ទាំងសិលាដ៏ធំពីព្រៃហេមពាន្ត ។ សូម្បីភិក្ខុទាំងឡាយ ក៏ហោះឡើងមក ដោយឫទ្ធិរបស់ខ្លួនឯង មកចុះក្នុងព្រៃមហាវ័ន នាំដែនសក្កៈជាមួយព្រះបរមសាស្តា ។

ក្នុងព្រៃមហាវ័ននោះ ព្រះអង្គបានបង្រៀននូវកម្មដ្ឋាន ដែលជាគោលអាចកម្ចាត់កិលេសបាន ។ ពួកភិក្ខុទាំងនោះ ទទួលយកកម្មដ្ឋានហើយ ក៏បែកគ្នាទៅគង់តាមគល់ឈើ ជាទីសប្បាយរបស់ខ្លួនរៀងៗខ្លួន ហើយមានសេចក្តីព្យាយាមផ្តួងឡើង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះថា ពួកភិក្ខុទាំងនេះ មិនលះបង់នូវការងារ កាលតាំងវិបស្សនាហើយ នឹងសម្រេចនូវអរហត្ត ហើយនឹងមកកាន់សំណាក់តថាគត ដើម្បីប្រាប់នូវគុណវិសេសដល់តថាគត ។ កាលភិក្ខុទាំងនោះមក ពួកទេវតាមួយម៉ឺនចក្កវាឡ នឹងមកប្រជុំគ្នាក្នុងព្រៃមហាវ័ននេះ ។ ការប្រជុំដ៏ធំនឹងមានក្នុងទីនេះ បើដូច្នេះ គួរតែតថាគតគង់ក្នុងទីដ៏ស្ងាត់ ។

ព្រះថេរៈដែលទទួលកម្មដ្ឋានមុនគេ ក៏បានសម្រេចនូវព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា ។ ការសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា ក៏មានតាមលំដាប់រហូតព្រះថេរៈទី ៥០០ ។ ព្រះថេរៈទាំងនោះក៏មកក្រាបទូលព្រះដ៏មានព្រះភាគតាមលំដាប់រហូតគ្រប់ព្រះអង្គ ។

ក្នុងរាត្រី ១៥ កើត ពេញបូណ៌មី (ខែជេស្ឋ?) ព្រះចន្ទរះឡើងមានពន្លឺភ្លឺចិញ្ចែងចិញ្ចាច ព្រះពុទ្ធជាអម្ចាស់ គង់នៅក្នុងព្រៃមហាវ័ន មួយអន្លើដោយ

ព្រះភិក្ខុ ៥០០ អង្គ សុទ្ធតែជាព្រះអរហន្ត ។ ព្រះពុទ្ធប្រសូតក្នុងត្រកូលក្សត្រ ពួកភិក្ខុទាំងនោះ ក៏ប្រសូតក្នុងត្រកូលក្សត្រដែរ ព្រះពុទ្ធទ្រង់សាងផ្នួស ពួកភិក្ខុទាំងនោះ ក៏សុទ្ធតែជាអ្នកបួសដែរ ព្រះពុទ្ធទ្រង់លះបង់ស្វេតច្ឆត្រ ពួកភិក្ខុទាំងនោះ ក៏សុទ្ធតែលះបង់ស្វេតច្ឆត្រដែរ ព្រះពុទ្ធទ្រង់បរិសុទ្ធ ពួកភិក្ខុទាំងនោះ ក៏សុទ្ធតែជាអ្នកបរិសុទ្ធដែរ ព្រះពុទ្ធទ្រង់មិនមានរាគៈ ទោសៈ និងមោហៈ ពួកភិក្ខុទាំងនោះ ក៏មិនមានរាគៈ ទោសៈ និងមោហៈដែរ ព្រះពុទ្ធទ្រង់មិនមានតណ្ហា ពួកភិក្ខុទាំងនោះ ក៏មិនមានតណ្ហាដែរ ។

ពួកទេវតានៅជុំវិញក្នុងព្រៃមហាវ័ន បានស្រែកប្រកាសសំឡេងយ៉ាងខ្លាំងថា នែ៎អ្នកដ៏ចម្រើនទាំងឡាយ ឈ្មោះថា ការឃើញព្រះពុទ្ធជាម្ចាស់ មានឧបការៈច្រើន ការស្តាប់ព្រះធម៌ មានឧបការៈច្រើន ការឃើញពួកភិក្ខុ មានឧបការៈច្រើន មកចុះពួកយើង មកនមស្ការព្រះពុទ្ធជាម្ចាស់ និងពួកព្រះខីណាស្រព ដែលបានទមុះអរហត្ត ហើយនាំគ្នាមកឈរក្នុងទីដ៏សមគួរ ។ ដោយសំឡេងប្រកាសតៗគ្នា ពួកទេវតាមួយម៉ឺនចក្កវាឡបានមកប្រជុំគ្នាហើយ ។ ពួកទេវតាទាំងឡាយក្នុងចក្កវាឡទាំងអស់ ដែលស្ថិតនៅក្នុងសកលជម្ពូទ្វីប បុព្វវិទេហទ្វីប អបរគោយានទ្វីប និង ឧត្តរកុរុទ្វីប ក្នុងទ្វីបតូច ២,០០០ ពួកទេវតាអាស្រ័យនៅក្នុងព្រៃហេមពាន្ត ពួកទេវតាដែលនៅក្នុងក្រុង ១៨៩,០០០ ក្រុង ពួកទេវតាដែលនៅក្នុងទោណមុខ ៩,៩០០,០០០ កន្លែង ពួកទេវតានៅបដ្ដនៈ ៩៦ សែនកោដិ ពួកទេវតានៅសមុទ្រ ៥៦ កន្លែង មកប្រជុំគ្នា រហូតដល់ទេវតាចំនួន ១០ លោកធាតុ

គឺ មួយម៉ឺនចក្កវាឡ ។ ចាប់ពីផ្ទៃចក្កវាឡ រហូតដល់ព្រហ្មលោក ណែនណាន់តាន់តាប់ដោយពួកទេវតានិងព្រហ្មទាំងឡាយ ។ ពួកទេវតានិម្មិតខ្លួនតូចៗ សូម្បីទីប៉ុនចុងរោមទ្រាយ ក៏មានទេវតា ១០ ទៅ ២០ ឬ ៣០ ឬក៏៤០ នាក់ដែរ ។ កាលណោះ មានព្រហ្ម ៤ អង្គ នៅជាន់សុទ្ធាវាស បានចូលសមាបត្តិ ។ កាលចេញពីសមាបត្តិវិញ ក៏ឃើញព្រហ្មលោក ជាន់សុទ្ធាវាស ស្ងាត់សូន្យឈឹង ក៏ពិចារណាមើលឃើញពួកព្រហ្មនិងទេវតានាំគ្នាមកកាន់ព្រៃមហាវ័ន ដើម្បីឃើញព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ ។ ពួកព្រហ្មទាំងនោះ ក៏តែងគាថាមួយនាក់ៗ មួយ ដើម្បីមកគាល់ព្រះពុទ្ធជាអម្ចាស់ ។

ព្រហ្មមួយអង្គ ស្ថិតនៅមាត់កណ្ដាប់ចក្កវាឡខាងកើត ចូលនីលកកសិណ មានរស្មីពណ៌ខៀវ ដូចពាក់ស្បែកកែវមណី ហើយឲ្យទេវតា មួយម៉ឺនចក្កវាឡជ្រាបថា ខ្លួនមកហើយ ក៏បានអណ្ដែតមកដោយឫទ្ធិ មកដល់ទីព្រះអង្គគង់ ក៏ក្រាបថ្វាយបង្គំព្រះពុទ្ធជាអម្ចាស់ ឈរក្នុងទីដ៏សមគួរ ហើយពោលគាថាថា

មហាសមយោ បវនស្មិំ
ទេវកាយា សមាគតា
អាគតម្ហ ឥមំ ធម្មសមយំ
ទក្ខិតាយេ អបរាជិតសង្ឃំ។

ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងដងព្រៃ ពួកទេវតាក៏មក
ប្រជុំគ្នាហើយយើងទាំងឡាយ (លុះឃើញពួកទេវតាប្រជុំ

គ្នាយ៉ាងនេះហើយ) ក៏នាំគ្នាមកកាន់ទីប្រជុំប្រកបដោយធម៌
នេះដើម្បីឃើញនូវអបរាជិតសង្ឃគឺសង្ឃដែលមារផ្ចាញ់
មិនបាន។

ព្រហ្មមួយអង្គ ស្ថិតនៅមាត់កណ្តាប់ចក្កវាឡខាងត្បូង ចូលបីតកកសិណ មានរស្មីពណ៌មាស ដូចដណ្តាប់សំពត់ពណ៌មាស ហើយឲ្យទេវតាមួយម៉ឺនចក្កវាឡជ្រាបថា ខ្ញុំមកហើយ ក៏បានអណ្តែតមកដោយឫទ្ធិ មកដល់ទីព្រះអង្គគង់ ក៏ក្រាបថ្វាយបង្គំព្រះពុទ្ធជាអម្ចាស់ ឈរក្នុងទីដ៏សមគួរ ហើយពោលគាថាថា

តត្រ ភិក្ខវោ សមាទហំសុ
ចិត្តមត្តនោ ឧជុកំ អកំសុ
សារថីវ នេត្តានិ គហេត្វា
ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតា។

ពួកភិក្ខុក្នុងទីប្រជុំនោះប្រកបដោយសមាធិ ធ្វើចិត្តរបស់ខ្លួន
(ដែលវៀចកោង) ឲ្យជាចិត្តស្លូតត្រង់ភិក្ខុជាបណ្ឌិតទាំង
ឡាយតែងរក្សានូវឥន្ទ្រិយ (ដោយល្អ) ដូចជានាយសារថី
ដែលកាន់ទប់នូវខ្សែបរទុកដូច្នោះឯង។

ព្រហ្មមួយអង្គ ស្ថិតនៅមាត់កណ្តាប់ចក្កវាឡខាងលិច ចូលលោហិតកសិណ មានរស្មីពណ៌ក្រហម ដូចដណ្តាប់សំពត់រោមសត្វពណ៌ក្រហម

ហើយឲ្យទេវតាមួយម៉ឺនចក្កវាឡជ្រាបថា ខ្ញុំមកហើយ ក៏បានអណ្ដែតមកដោយឫទ្ធិ មកដល់ទីព្រះអង្គគង់ ក៏ក្រាបថ្វាយបង្គំព្រះពុទ្ធជាអម្ចាស់ ឈរក្នុងទីដ៏សមគួរ ហើយពោលគាថាថា

ឆេត្វា ខីលំ ឆេត្វា បលិឃំ
ឥន្ទខីលំ ឩហច្ច មនេជា
តេ ចរន្តិ សុទ្ធា វិមលា
ចក្ខុមតា សុទន្តា សុសុនាគា ។

ពួកភិក្ខុទាំងនោះកាត់បង់នូវដែកគោល (រាគៈ ទោសៈ មោហៈ) កាត់បង់នូវរនុកទ្វារ (រាគៈ ទោសៈ មោហៈ) គាស់រំលើងនូវសសរគោល (រាគៈ ទោសៈ មោហៈ) ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រជាអ្នកបរិសុទ្ធស្អាតប្រាសចាកមន្ទិលជានាគកំលោះដែលព្រះពុទ្ធជាម្ចាស់ប្រកបដោយចក្ខុ ៥ ទ្រង់ទូន្មានល្អហើយតែងត្រាច់ទៅបានក្នុងទិសទាំង ៤ មិនមានទើសទាល់ ។

ព្រហ្មមួយអង្គ ស្ថិតនៅមាត់កណ្ដាប់ចក្កវាឡខាងជើង ចូលឱទាតកសិណ មានរស្មីពណ៌ស ដូចដណ្ដាប់សំពត់ពណ៌ផ្កាម្លិះ ហើយឲ្យទេវតាមួយម៉ឺនចក្កវាឡជ្រាបថា ខ្ញុំមកហើយ ក៏បានអណ្ដែតមកដោយឫទ្ធិ មកដល់ទីព្រះអង្គគង់ ក៏ក្រាបថ្វាយបង្គំព្រះពុទ្ធជាអម្ចាស់ ឈរក្នុងទីដ៏សមគួរ ហើយពោលគាថាថា

យេកេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តិ។

*ពួកជនណាមួយបានដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកហើយ ពួកជននោះឯងនឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពួកនៃទេវតាមិនខាន។*

*ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់មានព្រះញាណគ្មានអ្វីរាំងបាន ទ្រង់បានចែកពួកទេវតាទាំងនោះ ជាពីរចំណែក គឺអភព្វទេព ១ ភព្វទេព ១ ។ អភព្វទេព គឺសត្វដែលមិនមានឧបនិស្ស័យនឹងត្រាស់ដឹងនូវអរិយសច្ចបានដោយអំណាចអរិយមគ្គ ។ ភព្វទេព គឺពួកសត្វដែលមានឧបនិស្ស័យត្រាស់ដឹងដោយអរិយមគ្គ ។ ពួកភព្វទេពនេះ មាន ៦ ពួក គឺពួករាគចរិត ១ ពួកទោសចរិត ១ ពួកមោហចរិត ១ ពួកវិតក្កចរិត ១ ពួកសទ្ធាចរិត ១ ពួកពុទ្ធិចរិត ១ ។*

*ព្រះពុទ្ធជាអម្ចាស់ ទ្រង់ជ្រាបថា សត្វទាំងនេះ ត្រាស់ដឹងក្នុងធម៌ដែលជាធម៌ សាកសួរ និងវិស្សជ្ជនា មិនអាចត្រាស់ដឹងដោយធម្មីកថាដែលមិនមានសំនួរ និងចម្លើយនោះទេ ។ តើបុគ្គលណា សមគួរដល់ការសាកសួរបញ្ហាព្រះធម៌ទាំងនេះបាន ? ទ្រង់ពិចារណាមិនឃើញមានវិស័យរបស់បុគ្គលណាមួយ អាចសួរបញ្ហានេះបានឡើយ ក្រៅពីព្រះពុទ្ធជាអម្ចាស់ ។*

កាលណោះ ព្រះពុទ្ធបរមគ្រូ ទ្រង់ចូលឈាន មានអភិញ្ញាជាបាទ ហើយបរិកម្មដោយកាមាវចរចិត្ត និម្មិតព្រះពុទ្ធមួយព្រះអង្គ ដែលមានបាត្រនិងចីវរ ការឈានដើរ ផាកព្រះភក្ត្រ ជាដើម ហើយទ្រង់អធិដ្ឋានដោយរូបាវចរចិត្ត ឲ្យមានពន្លឺដូចដួងព្រះចន្ទអណ្តែតចេញពីកំពូលភ្នំយុគន្ធរ ឯទិសខាងកើត ។

គ្រានោះ ពួកទេវតាទាំងឡាយ ឃើញព្រះពុទ្ធនិម្មិត ក៏និយាយគ្នាថា ព្រះចន្ទរះឡើងមួយដួងទៀតហើយ ។ កាលព្រះពុទ្ធនិម្មិតយាងចូលមកជិត ក៏គិតថា ពន្លឺនេះ មិនមែនព្រះចន្ទទេ គឺជាពន្លឺព្រះអាទិត្យ ។ កាលព្រះពុទ្ធនិម្មិតខិតចូលមកជិត ក៏សម្គាល់ថា នុ៎ះជាវិមានទេវតា, នុ៎ះជាទេវបុត្រ, នុ៎ះជាមហាព្រហ្ម ។ ស្រាប់តែមកជិតកាលណា ក៏ប្រាកដឃើញព្រះពុទ្ធមួយព្រះអង្គទៀត ដែលមានមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ ឆព្វណ្ណរង្សី ៦ ប្រការ ដូចគ្នានឹងព្រះពុទ្ធដែលកំពុងគង់នៅក្នុងព្រៃមហាវ័ន។ ព្រះពុទ្ធនិម្មិតបានយាងមកដល់ហើយ មិនថ្វាយបង្គំព្រះពុទ្ធជាម្ចាស់ឡើយ ក៏គង់ក្នុងទីស្មើគ្នា នឹងព្រះពុទ្ធជាម្ចាស់ ។ ព្រះរស្មីនៃព្រះពុទ្ធទាំងពីរព្រះអង្គ ក៏ជះដល់គ្នាទៅវិញ ទៅមក ។ ឆព្វណ្ណរង្សី ក៏មានពន្លឺលើសលុបជាងពន្លឺព្រហ្ម និងទេវតាទាំងឡាយ រហូតដល់ជាន់អកនិដ្ឋ ។ ពេលនោះ ពួកទេវតាបុថុជ្ជន គិតថា ព្រះពុទ្ធមួយអង្គ អស្ចារ្យម៉្លឹងទៅហើយ ចុះឥឡូវព្រះពុទ្ធមានដល់ទៅពីរព្រះអង្គ គឺជាការអស្ចារ្យណាស់ ។ ពួកទេវតាដែលជាអរិយៈជ្រាបថា ធម្មតាពុទ្ធុប្បាទ មិនមានព្រះពុទ្ធដទៃត្រាស់ដឹងដំណាលគ្នានោះទេ នេះជាព្រះពុទ្ធនិម្មិតដែលព្រះពុទ្ធទ្រង់សាងឡើង ។

ព្រះពុទ្ធនិម្មិតសួរបញ្ហាព្រះធម៌ និងព្រះពុទ្ធទ្រង់ឆ្លើយបញ្ហាព្រះធម៌ ដែលជាប់ទាក់ទងដោយចរិតទាំង ៦ របស់សត្វលោក ក្នុងព្រៃមហាវ័ន នាកាលប្រជុំដ៏ធំ ។

សម្មាបរិព្វាជនីយសូត្រ សម្រាប់ពួកទេវតាជារាគចរិត ដែលមាន ក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ១១៤ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

កលហវិវាទសូត្រ ពួកទេវតាដែលជាទោសចរិតដែលមានក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ២៩០ ។ ព្រះសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានពង្រីកសេចក្តីជាបែបអដ្ឋកថាយ៉ាងពីរោះ ក្នុងមហានិទ្ទេស បិដកលេខ ៦៥ ចាប់ពីទំព័រ ១៤២ រហូតដល់ទំព័រ ២០៤ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

មហាវិយូហសូត្រ[១] ពួកទេវតាដែលជាមោហចរិត ដែលមានក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៣០១។ ព្រះសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានពង្រីកសេចក្តីជាបែបអដ្ឋកថាយ៉ាងពីរោះ ក្នុងមហានិទ្ទេស បិដកលេខ ៦៥ ចាប់ពីទំព័រ ២៤៧ រហូតដល់ទំព័រ ៣១៤ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

---

១ ច្បាប់ឆដ្ឋសង្គាយនាថា មហាព្យូហសូត្រ ។

ចូឡរាហុលោវាទសូត្រ[១] ពួកទេវតា ដែលជាវិតក្កចរិត ដែលមានក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ២៩៦។ ព្រះសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានពង្រីកសេចក្តីជាបែបអដ្ឋកថាយ៉ាងពីរោះ ក្នុងមហានិទ្ទេស បិដកលេខ ៦៥ ចាប់ពីទំព័រ ២០៥ រហូតដល់ទំព័រ ២៤៦ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

តុវដកសូត្រ ពួកទេវតា ដែលជាសទ្ធាចរិត ដែលមានក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ៣០៧ ។ ព្រះសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានពង្រីកសេចក្តីជាបែបអដ្ឋកថាយ៉ាងពីរោះ ក្នុងមហានិទ្ទេស បិដកលេខ ៦៦ ចាប់ពីទំព័រ ១ រហូតដល់ទំព័រ ១២០ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

បុរាភេទសូត្រ ពួកទេវតា ដែលជាពុទ្ធិចរិត ដែលមានក្នុង ខុទ្ទកនិកាយ សុត្តនិបាត បិដកលេខ ៥៤ ទំព័រ ២៨៧ ។ ព្រះសូត្រនេះ ព្រះធម្មសេនាបតីសារីបុត្រ បានពង្រីកសេចក្តីជាបែបអដ្ឋកថាយ៉ាងពីរោះ ក្នុងមហានិទ្ទេស បិដកលេខ ៦៥ ចាប់ពីទំព័រ ៥១ រហូតដល់ទំព័រ ១៤១ ។ កាលព្រះពុទ្ធសម្តែងធម៌នេះចប់ ពួកទេវតាមួយសែនកោដិនាក់បានសម្រេចព្រះអរហន្តរួចផុតអាសវក្កិលេស ។

---

១ច្បាប់ឆដ្ឋសង្គាយនាថា ចូឡព្យូហសូត្រ ។

ក្នុងកាលណោះ ពួកទេវតាដែលមានសក្តិតូចគិតថា ព្រះដ៏មានព្រះភាគព្រះអង្គ នឹងចង្អុលបង្ហាញតែទេវតាដែលមានសក្តិធំប៉ុណ្ណោះ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់ជ្រាបដំណើរនោះហើយ ក៏បង្ហាញឲ្យភិក្ខុទាំងឡាយព្យាយាមសំឡឹងមើលមើលពួកទេវតាទាំងឡាយ ដូចមានសេចក្តីពិស្តារក្នុងធម៌ មហាសមយសូត្រ ទីឃនិកាយ មហាវគ្គ បិដកលេខ ១៧ ទំព័រ ១៦៨ និង មានសេចក្តីអធិប្បាយយ៉ាងច្បាស់ក្នុងអដ្ឋកថា សុមង្គល-វិលាសិនី ។ មានសេចក្តីសង្ខេបក្នុង សមយសូត្រ សំយុត្តនិកាយ សតុល្លប្បកាយិកវគ្គ បិដកលេខ ២៩ ទំព័រ ៦៥ ។

ព្រះធម៌ទាំងនេះ មានសារៈសំខាន់ណាស់ សម្រាប់ពុទ្ធសាសនិក សូមមេត្តាយកចិត្តទុកដាក់ទន្ទេញឲ្យបានចាំ ដើម្បីជាឧបនិស្ស័យនៃការបានសម្រេចព្រះនិព្វាន រួចផុតចាកអាសវក្កិលេស ។

សូមអនុមោទនា !

១

# អត្តទណ្ឌសូត្រ

## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/៣០១)

អត្តទណ្ឌា ភយំ ជាតំ ជនំ បស្សថ មេធកំ
សំវេគំ កិត្តយិស្សាមិ យថា សំវិជិតំ មយា ។

*ភ័យកើតមកពីអាជ្ញារបស់ខ្លួន ( សេចក្តីប្រព្រឹត្តកាចអាក្រក់របស់ខ្លួន ) អ្នកទាំងឡាយ ចូរមើលជនអ្នកទាស់ទែងគ្នា តថាគត ( កាលនៅជាពោធិសត្វ ) បានតក់ស្លុតហើយ យ៉ាងណា តថាគតនឹងសម្តែងនូវសេចក្តីតក់ស្លុត យ៉ាងនោះ (ដល់អ្នកទាំងឡាយ ) ។*

ផន្ទមានំ បជំ ទិស្វា មច្ឆេ អប្បោទកេ យថា
អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា មំ ភយមាវិសិ ។

*ភ័យមកកាន់តថាគត ព្រោះឃើញនូវពួកសត្វ កំពុងញាប់ញ័រ ( ដោយតណ្ហាជាដើម ) ដូចពួកមច្ឆជាតិ ក្នុងទីមានទឹកតិច ព្រោះឃើញសត្វលោកបៀតបៀនគ្នានឹងគ្នា ។*

សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា
ឥច្ឆំ ភវនមត្តនោ នាទ្ទសាសិំ អនោសិតំ ។

*លោកមិនមានខ្លឹមសារដោយជុំវិញ ទិសទាំងពួង រមែងញាប់ញ័រ តថាគតកាលប្រាថ្នានូវភព ( ជាទីពឹង ) របស់ខ្លួន ក៏មិនបានឃើញភពណាមួយ ដែលជរាធម៌ជាដើម ជិះជាន់មិនបាន ។*

ឱសានេត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ
អថេត្ថ សល្លមទ្ទក្ខិំ ទុទ្ទសំ ហទយនិស្សិតំ។

*សេចក្តីមិនរីករាយ បានកើតមានដល់តថាគតហើយ ព្រោះបានឃើញសត្វទាំងឡាយ ត្រូវជរាជាជាដើម បៀតបៀនហើយ ក្នុងកាលជាទីបំផុត តពីនោះមក តថាគតបានឃើញសរ ដែលគេឃើញបានដោយកម្រ អាស្រ័យនៅក្នុងហឫទ័យ ក្នុងសត្វទាំងឡាយនោះ ។*

យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ
តមេវ សល្លមព្ពុយ្ហ ន ធាវតិ ន សីទតិ។

*សត្វលោកដែលសរដោតជាប់ហើយ រមែងស្ទុះទៅកាន់ទិសផ្សេង ៗ បុគ្គលជាបណ្ឌិត ដកសរនោះបាន ទើបមិនស្ទុះទៅ មិនលិចចុះ ។*

តត្ថ សិក្ខានុគីយន្តិ
(យានិ លោកេ គធិតានិ) ន តេសុ បសុតោ សិយា
និព្វិជ្ឈ សព្វសោ កាមេ សិក្ខេ និព្វានមត្តនោ។

*( អារម្មណ៍ជាទីស្រឡាញ់ គឺបញ្ចកាមគុណណា មានក្នុងលោក ) ប្រជុំជន តែងសម្តែងនូវកាសិត ជាគ្រឿងសិក្សា ( មានការសិក្សាដំរីជាដើម ) ដើម្បីឲ្យបានអារម្មណ៍ជាទីស្រឡាញ់នោះ បណ្ឌិតមិនគួរខ្វល់ខ្វាយ ក្នុងបញ្ចកាមគុណ ឬក្នុងកិច្ចសិក្សានោះឡើយ គប្បីនឿយណាយក្នុង*

*កាមារម្មណ៍ ដោយប្រការទាំងពួង គប្បីសិក្សានូវព្រះនិព្វាន*
*បម្រុងខ្លួន ។*

សច្ចោ សិយា អប្បគព្ភោ   អមាយោ រិត្តបេសុណោ
អក្កោធនោ លោភបាបំ   វេវិច្ឆំ វិតរេ មុនិ។

*បុគ្គលជាអ្នកប្រាជ្ញ គប្បីជាអ្នកមានសច្ចៈ ជាបុគ្គលមិន*
*ឃ្មើសឃ្មង មិនមានមាយា លះបង់ពាក្យញុះញង់*
*មិនក្រេវក្រោធ ឆ្លងឲ្យរួចនូវលោភៈដ៏លាមក និងមច្ឆរិយ ។*

និទ្ទំ តន្ទិំ សហេ ថីនំ   បមាទេន ន សំវសេ
អតិមានេ ន តិដ្ឋេយ្យ   និព្វានមនសោ នរោ ។

*នរជន មានចិត្តឱនទៅរកព្រះនិព្វាន គប្បីគ្របសង្កត់នូវការ*
*ដេកលក់ សេចក្ដីខ្ជិលច្រអូស ការរួញរា មិនគប្បីជំអក់នៅ*
*ដោយសេចក្ដីប្រហែសធ្វេស  មិនគប្បីតាំងខ្លួនក្នុងមានៈ*
*ដ៏ក្រៃលែង ។*

មោសវជ្ជេ ន និយេថ   រូបេ ស្នេហំ ន កុព្វយេ
មានញ្ច បរិជានេយ្យ   សាហសា វិរតោ ចរេ។

*បុគ្គលអ្នកបង្អោនចិត្តទៅរកព្រះនិព្វាន មិនគប្បីដឹកនាំ ក្នុង*
*ពាក្យមុសាវាទ មិនគប្បីធ្វើសេចក្ដីស្នេហាក្នុងរូប ត្រូវកំណត់*
*ដឹងនូវមានៈហើយគប្បីវៀរចេញចាកអំពើដ៏រួសរាន់ ។*

បុរាណំ នាភិនន្ទេយ្យ   នវេ ខន្តិំ ន កុព្វយេ
ហិយ្យមានេ ន សោចេយ្យ អាកាសំ ន សិតោ សិយា។

មិនគប្បីស្រើបស្រាលទៅរកបញ្ចក្ខន្ធ ដែលជារបស់ចាស់ គឺជាអតីតៈ មិនគប្បីធ្វើសេចក្តីពេញចិត្តនឹងបញ្ចក្ខន្ធ ដែលជារបស់ថ្មី គឺជាបច្ចុប្បន្ន មិនត្រូវសោកស្តាយនឹងបញ្ចក្ខន្ធ ដែលសាបរលាបទៅហើយ មិនត្រូវជាប់ស្អិតនៅក្នុងតណ្ហា ។

គេធំ ព្រូមិ មហោឃោតិ    អាជវំ ព្រូមិ ជប្បនំ
អារម្មណំ បកប្បនំ    កាមបង្កោ ទុរច្ចយោ។

តថាគតពោលនូវសេចក្តីជាប់ចិត្ត គឺតណ្ហា ថាជាអន្លង់ធំ តថាគតពោលនូវសេចក្តីជក់ចិត្ត គឺតណ្ហា ថាជាគ្រឿងលឿនទៅនៃចិត្ត ថាជាគ្រឿងជាប់ញ៉ាមនៅនៃចិត្តថា ជាអារម្មណ៍នៃចិត្ត ថាជាគ្រឿងត្រិះរិះ ( ព្រោះ ) កាមតណ្ហាដូចជាភក់ សត្វទាំងឡាយ អាចឆ្លងបានដោយលំបាក ។

សច្ចា អវោក្កម្ម មុនិ    ថលេ តិដ្ឋតិ ព្រាហ្មណោ
សព្វំ សោ បដិនិស្សជ្ជ    ស វេ សន្តោតិ វុច្ចតិ។

អ្នកប្រាជ្ញ ជាព្រាហ្មណ៍ មិនគេចចេញចាកសច្ចៈ រមែងតាំងនៅលើទីទួល គឺព្រះនិព្វាន តថាគតហៅបុគ្គល នោះថាជាអ្នកស្ងប់ ព្រោះលះអាយតនៈទាំងអស់ ។

ស វេ វិទ្វា ស វេទគូ    ញត្វា ធម្មំ អនិស្សិតោ
សម្មា សោ លោកេ ឥរិយានោ    ន បិហេតីធ កស្សចិ។

បុគ្គលនោះ ជាអ្នកប្រាជ្ញ បុគ្គលនោះ ជាអ្នកដល់នូវវេទ ជាបុគ្គលដែលតណ្ហា និងទិដ្ឋិ មិនអាស្រ័យនៅហើយ ព្រោះ

ឃើញសង្ខារធម៌ ( ថាជារបស់មិនទៀង ជាទុក្ខ មិនមែនខ្លួន ) បុគ្គលនោះ រមែងប្រព្រឹត្តនៅក្នុងលោកដោយប្រពៃ មិនជាប់ចិត្តនឹងបុគ្គលណាមួយឡើយ ។

យោធ កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ
ន សោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោ ។

បុគ្គលណា បានឆ្លងផុតនូវកាមផង នូវកិលេសគ្រឿងជាប់ដែលឆ្លងបានដោយកម្រ ក្នុងលោកផង បុគ្គលនោះ ឈ្មោះថា កាត់ខ្សែតណ្ហា មិនមានចំណង រមែងមិនសោក មិនសុបសៅ ។

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

កិលេសជាតណ្ហា កើតឡើង ( ព្រោះប្រារព្ធ ) សង្ខារជាអតីត: អ្នកចូរធ្វើកិលេសនោះ ឲ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ ( មានរាគ:ជាដើម កើតឡើងព្រោះប្រារព្ធ ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល ( មានរូបជាដើម ដែលជាបច្ចុប្បន្ន ) អ្នកនឹងទៅជាបុគ្គលស្ងប់ ។

សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ លោកេ ន ជីយតិ ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាម និងរូប ថាជា

របស់អញ សព្វកន្លែងទេ បុគ្គលនោះឯង រមែងមិនសោក ព្រោះនាមរូបដែលមិនមានផង មិនទ្រុឌទ្រោមទៅក្នុងលោកផង ។

យស្ស នត្ថិ ឥទំ មេតិ    បរេសំ វាបិ កិញ្ចនំ
មមត្តំ សោ អសំវិន្ទំ    នត្ថិ មេតិ ន សោចតិ។

កន្សល់ថា នេះរបស់អញ នុ៎ះជារបស់ជនដទៃ មិនមានដល់បុគ្គលណា បុគ្គលនោះ កាលមិនបានទូវវត្ថុដែលប្រកាន់ថារបស់អញ រមែងមិនសោកថា អញគ្មានដូច្នេះឡើយ ។

អនិដ្ឋុរី អននុគិទ្ធោ    អនេជោ សព្វធី សមោ
តមានិសំសំ បព្រូមិ    បុច្ឆិតោ អវិកម្បិនំ។

បុគ្គលដែលមិនមានប្ញស្សា មិនមានសេចក្ដីត្រេកអរ ជាអ្នកមិនញាប់ញ័រ ជាអ្នកស្ងប់រម្ងាប់ ក្នុងអាយតនៈខាងក្នុងខាងក្រៅទាំងអស់ តថាគត កាលបើមានបុគ្គលចូលមកសួរអានិសង្ស របស់បុគ្គលអ្នកមិនញាប់ញ័រនោះ ក៏នឹងសម្ដែង ( អានិសង្សទាំង ៤ មានមិនប្ញស្សាជាដើមនោះ ) ។

អនេជស្ស វិជានតោ    នត្ថិ កាចិ និសង្ខតិ
វិរតោ សោ វិយារព្ភា    ខេមំ បស្សតិ សព្វធិ។

បណ្ដាសង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម ) សង្ខារណាមួយ មិនមានដល់បុគ្គលអ្នកមិនញាប់ញ័រ អ្នកដឹងច្បាស់ ( នូវត្រៃលក្ខណ៍ ) បុគ្គលនោះ វៀរស្រឡះចាកសង្ខារទាំង ៣ នោះ រមែងឃើញសេចក្ដីក្សេមក្នុងទីទាំងពួង ។

ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនិ
សន្តោ សោ វីតមច្ឆរោ នាទេតិ ន និរស្សតីតិ ។

*អ្នកប្រាជ្ញ រមែងមិននិយាយអួតខ្លួន ( ដោយមានះថា អញជាបុគ្គលស្មើគ្នា ) ក្នុងពួកបុគ្គលស្មើគ្នា ( ថាអញជាបុគ្គលថោកទាប ) ក្នុងពួកបុគ្គលដែលថោកទាប ( ថាអញជាបុគ្គលប្រសើរ) ក្នុងពួកបុគ្គលដែលប្រសើរ បុគ្គលនោះជាអ្នកស្ងប់ប្រាសចាកសេចក្តីកំណាញ់ រមែងមិនប្រកាន់ មិនអន្ទះសារ ។*

អត្តទណ្ឌសុត្តំ និដ្ឋិតំ ។ *ចប់ អត្តទណ្ឌសូត្រ ។*

# មហាសមយសុត្ត

ឯវម្មេ សុតំ ។ *សូត្រនេះ ឈ្មោះថា មហាសមយសូត្រ គឺខ្ញុំឈ្មោះ អានន្ទ បានស្តាប់មកហើយយ៉ាងនេះថា ។*

ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។*

ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ *ទេវតាទាំងឡាយ ក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគនិងភិក្ខុសង្ឃ ។*

អថ ខោ ចតុន្នំ សុទ្ធាវាសកាយិកានំ ទេវតានំ ឯតទហោសិ *គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងជាន់សុទ្ធាវាស ៤ អង្គ មានសេចក្តីត្រិះរិះដូច្នេះថា*

អយំ ខោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ *ព្រះដ៏មានព្រះភាគនេះ ព្រះអង្គគង់នៅក្នុងព្រៃមហាវ័ន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។*

ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ *ទេវតាទាំងឡាយ ក៏មកអំពី*

*លោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះដ៏មានព្រះភាគនិង ព្រះភិក្ខុសង្ឃ ។*

យន្នូន មយម្បិ យេន ភគវា តេនុបសង្កមេយ្យាម; ឧបសង្កមិត្វា ភគវតោ សន្តិកេ បច្ចេកំ គាថំ ភាសេយ្យាមា”តិ។ *បើដូច្នេះគួរតែយើងទាំងអស់គ្នា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ គប្បីពោលនូវគាថាមួយនាក់មួយដងៗ ក្នុងសម្នាក់នៃព្រះដ៏មាន ព្រះភាគ ។*

អថ ខោ តា ទេវតា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ, ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា ភគវតោ បុរតោ បាតុរហេសុំ។ *លំដាប់នោះ ទេវតាទាំងនោះឯង ក៏បាត់អំពីសុទ្ធាវាសព្រហ្មលោក មកប្រាកដ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ (ដោយឆាប់រហ័ស ) គួរនាដូចជាបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។*

អថ ខោ តា ទេវតា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ។ *គ្រានោះពួកទេវតានោះក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ។* ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ *លុះទេវតាទាំងនោះ ស្ថិតនៅក្នុងទីដ៏សមគួរហើយ ទើបទេវតាមួយអង្គ ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគថា*

មហាសមយោ បវនស្មិំ
ទេវកាយា សមាគតា
អាគតម្ហ ឥមំ ធម្មសមយំ

ឧក្ខិតាយេ អបរាជិតសង្ឃ"ន្តិ។
ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងដងព្រៃ ពួកទេវតាក៏
មកប្រជុំគ្នាហើយ យើងទាំងឡាយ (លុះ
ឃើញ ពួកទេវតាប្រជុំគ្នាយ៉ាងនេះហើយ)
ក៏នាំគ្នាមកកាន់ទីប្រជុំប្រកបដោយធម៌នេះ
ដើម្បីឃើញនូវអបរាជិតសង្ឃ គឺសង្ឃដែល
មារផ្ចាញ់មិនបាន ។

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ
លំដាប់នោះ ទេវតា មួយអង្គទៀត ក៏ពោលនូវគាថានេះក្នុងសម្នាក់នៃព្រះ
មានព្រះភាគថា

តត្រ ភិក្ខវោ សមាទហំសុ
ចិត្តមត្តនោ ឧជុកំ អកំសុ
សារថីវ នេត្តានិ គហេត្វា
ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតា"តិ។
ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិ
ធ្វើចិត្តរបស់ខ្លួន ( ដែលវៀចកោង ) ឲ្យជាចិត្ត
ស្លូតត្រង់ ភិក្ខុជាបណ្ឌិតទាំងឡាយ តែងរក្សានូវ
ឥន្ទ្រិយ ( ដោយល្អ ) ដូចជានាយសារថីដែល
កាន់ទប់នូវខ្សែបរទុកដូច្នោះឯង ។

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

*លំដាប់នោះ ទេវតា មួយអង្គទៀត ក៏ពោលនូវគាថានេះក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគថា*

ឆេត្វា ខីលំ ឆេត្វា បលិឃំ
ឥន្ទខីលំ ឩហច្ច មនេជា
តេ ចរន្តិ សុទ្ធា វិមលា
ចក្ខុមតា សុទន្តា សុសុនាគា”តិ ។

*ពួកភិក្ខុទាំងនោះ កាត់បង់នូវដែកគោល ( រាគៈ ទោសៈ មោហៈ ) កាត់បង់នូវរនុកទ្វារ ( រាគៈ ទោសៈ មោហៈ ) គាស់រំលើងនូវសសរគោល ( រាគៈ ទោសៈ មោហៈ ) ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ជាអ្នកបរិសុទ្ធស្អាត ប្រាសចាកមន្ទិល ជានាគកំលោះ ដែលព្រះពុទ្ធជាម្ចាស់ ប្រកបដោយចក្ខុ ៥ ទ្រង់ទូន្មានល្អហើយ តែងត្រាច់ទៅបានក្នុងទិសទាំង ៤ មិនមានទើសទាល់ ។*

អថ ខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

*លំដាប់នោះ ទេវតាមួយអង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគថា*

យេកេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តី”តិ។

*ពួកជនណាមួយ បានដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួក នៃទេវតាមិនខាន ។*

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ “យេភុយ្យេន ភិក្ខវេ ទសសុ លោកធាតូសុ ទេវតា សន្និបតិតា ហោន្តិ, តថាគតំ ទស្សនាយ ភិក្ខុសង្ឃញ្ច។ *លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនអន្គ ក្នុងលោកធាតុទាំង ១០ មកប្រជុំគ្នា ដើម្បីឃើញនូវតថាគតនិងភិក្ខុសង្ឃ ។*

យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា, តេសម្បិ ភគវន្តានំ ឯតំបរមាយេវ ទេវតា សន្និបតិតា អហេសុំ សេយ្យថាបិ មយ្ហំ ឯតរហិ។ *ម្នាលភិក្ខុទាំងឡាយ ព្រះដ៏មានព្រះភាគទាំងឡាយណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងហើយក្នុងអតីតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះដូចគ្នា មកប្រជុំគ្នា ដើម្បី*

ឃើញនូវព្រះដ៏មានព្រះភាគទាំងនោះ ដូចជាពួកទេវតា ដែលមកប្រជុំគ្នា ដើម្បីឃើញតថាគត ក្នុងកាលឥឡូវនេះដែរ ។

យេបិ តេ ភិក្ខវេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា, តេសម្បិ ភគវន្តានំ ឯតំបរមាយេវ ទេវតា សន្និបតិតា ភវិស្សន្តិ សេយ្យថាបិ មយ្ហំ ឯតរហិ។ ម្នាលភិក្ខុទាំងឡាយ ព្រះដ៏មានព្រះភាគទាំងឡាយណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ដែលនឹងបានត្រាស់ដឹងក្នុងអនាគតកាល ពួកទេវតាមានប្រមាណប៉ុណ្ណេះដូចគ្នា នឹងមកប្រជុំគ្នា ដើម្បីឃើញនូវព្រះដ៏មានព្រះភាគទាំងនោះ ដូចពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគតក្នុងកាលឥឡូវនេះដែរ ។

អាចិក្ខិស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ; កិត្តយិស្សាមិ, ភិក្ខវេ ទេវកាយានំ នាមានិ; ទេសេស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់នូវនាមនិងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោល នូវនាមនិងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវនាមនិងគោត្ររបស់ពួកទេវតាទាំងឡាយ ។

តំ សុណាថ, សាធុកំ មនសិករោថ, ភាសិស្សាមី"តិ ។ ចូរអ្នកទាំងឡាយ ប្រុងស្តាប់រឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងឲ្យស្តាប់ ។

ឯវំ ភន្តេ"តិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ។ ភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច ទើបព្រះមានព្រះភាគទ្រង់សម្តែងនូវភាសិតនេះថា

"សិលោកមនុកស្សាមិ យត្ថ ភុម្មា តទស្សិតា
យេ សិតា គិរិគព្ភរំ បហិតត្តា សមាហិតា។

*តថាគតនឹងធ្វើនូវស្លោក ភូមទេវតា ( ស្ថិតនៅ ) ក្នុងទីណា ពួកភិក្ខុក៏អាស្រ័យនូវទីនោះ ពួកភិក្ខុណា ដែលនៅអាស្រ័យនឹងផ្ទៃភ្នំ បញ្ជូនចិត្តទៅកាន់អារម្មណ៍ល្អ មានចិត្តតម្កល់នឹង ( តថាគតនឹងសម្តែងគុណនៃភិក្ខុទាំងនោះ ) ។*

បុថូសីហាវ សល្លីនា លោមហំសាភិសម្ភុនោ
ឱទាតមនសា សុទ្ធា វិប្បសន្នមនាវិលា ។

*ពួកភិក្ខុច្រើនរូប សម្ងំនៅក្នុងកម្មដ្ឋាន គ្របសង្កត់នូវការព្រឺរោមព្រឺស្បែក ( ឥតមានភ័យខ្លាច ) ដូចសត្វសីហៈ មានចិត្តផូរផង់ បរិសុទ្ធ ជ្រះថ្លាឥតមានល្អក់ឡើយ ។*

ភិយ្យោ បញ្ចសតេ ញត្វា វនេ កាបិលវត្ថវេ
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ។
ទេវកាយា អភិក្កន្តា តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមការុំ សុត្វា ពុទ្ធស្ស សាសនំ។

*លំដាប់នោះព្រះសាស្តាទ្រង់ជ្រាបនូវពួកព្រះអរហន្តជាង ៥០០ រូប នៅក្នុងដងព្រៃជិតក្រុងកបិលវត្ថុ ទើបទ្រង់ត្រាស់នឹងពួក ភិក្ខុជាសាវ័ក ដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកនៃទេវតាមានពន្លឺរស្មីដ៏រុងរឿង ( មកហើយ ) អ្នករាល់គ្នា ចូរ*

ស្គាល់នូវពួកទេវតាទាំងនោះ ( ដោយទិព្វចក្ខុញ្ញាណ ) ចុះឯពួកភិក្ខុទាំងនោះ បានស្តាប់នូវពាក្យប្រដៅនៃព្រះពុទ្ធជាម្ចាស់ ហើយក៏ធ្វើនូវការព្យាយាម ( ដើម្បីទិព្វចក្ខុញ្ញាណនោះ ) ។

តេសំ ចាតុរហុ ញាណំ អមនុស្សានទស្សនំ
អប្បេកេ សតមទ្ទក្ខុំ សហស្សំ អថ សត្តរឹ។

ទិព្វចក្ខុញ្ញាណ សម្រាប់មើលឃើញនូវពួកអមនុស្ស ( ទេវតា ) ក៏កើតមានប្រាកដ ដល់ពួកភិក្ខុទាំងនោះ ពួកភិក្ខុខ្លះ បានឃើញនូវអមនុស្ស ១.០០ ខ្លះបានឃើញនូវអមនុស្ស ១.០០០ ខ្លះបានឃើញនូវអមនុស្ស ៧០ពាន់ ។

សតំ ឯកេ សហស្សានំ អមនុស្សានមទ្ទសុំ
អប្បេកេនន្តមទ្ទក្ខុំ ទិសា សព្វា ផុដា អហុំ។

ពួកភិក្ខុខ្លះ បានឃើញនូវអមនុស្ស ១ សែន ខ្លះបានឃើញនូវអមនុស្សច្រើន ( មិនមានកំណត់ ) អមនុស្សទាំងនោះ ក៏ផ្សាយនៅពាសពេញក្នុងទិសទាំងពួង ។

តញ្ច សព្វំ អភិញ្ញាយ វវត្ថិត្វាន ចក្ខុមា
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ។
ទេវកាយា អភិក្កន្តា តេ វិជានាថ ភិក្ខវោ
យេ វោហំ កិត្តយិស្សាមិ គិរាហិ អនុបុព្វសោ។

លំដាប់នោះព្រះសាស្តាប្រកបដោយចក្ខុ ៥ ទ្រង់ពិចារណាហើយ ជ្រាបនូវហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់ នឹងពួកភិក្ខុជាសាវ័ក អ្នកត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួក

ទេវតាមានពន្លឺរស្មីរុងរឿង ( មកហើយ ) អ្នករាល់គ្នា ចូរស្គាល់ នូវពួកទេវតាទាំងនោះចុះ តថាគតនឹងប្រាប់ ( នូវទេវតាទាំងនោះ ) ដល់អ្នករាល់គ្នា ដោយពាក្យតាមលំដាប់ហូរហែ ។

សត្តសហស្សា តេ យក្ខា  ភុម្មា កាបិលវត្ថវា
ឥទ្ធិមន្តោ ជុតិមន្តោ  វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ  ភិក្ខូនំ សមិតិំ វនំ។

យក្សទាំង ៧ ពាន់ ជាភូមទេវតា អាស្រ័យនៅនាក្រុងកបិលវត្ថុ មានឫទ្ធិ មានអានុភាព មានសម្បុរកាយ មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

ឆសហស្សា ហេមវតា  យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ  វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ  ភិក្ខូនំ សមិតិំ វនំ។

ពួកយក្ស ៦ ពាន់ ដែលកើត នៅនាភ្នំហិមវន្ត មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

សាតាគិរា តិសហស្សា  យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ  វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ  ភិក្ខូនំ សមិតិំ វនំ។

ពួកយក្ស ៣ ពាន់ ដែលនៅអាស្រ័យនឹងភ្នំសាតាគិរី មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស

មានចិត្តរីករាយនាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

ឥច្ចេតេ សោឡសសហស្សា　យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　ភិក្ខូនំ សមិតឹ វនំ។

ពួកយក្ស ១៦ ពាន់នេះ មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

វេស្សាមិត្តា បញ្ចសតា　យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　ភិក្ខូនំ សមិតឹ វនំ។

ពួកយក្ស ដែលកើតនៅនាវេស្សាមិត្តបព៌ត មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ។

កុម្ភីរោ រាជគហិកោ　វេបុល្លស្ស និវេសនំ
ភិយ្យោ នំ សតសហស្សំ　យក្ខានំ បយិរុបាសតិ
កុម្ភីរោ រាជគហិកោ　សោបាគា សមិតឹ វនំ។

កុម្ភីរយក្ស ដែលកើតនៅនានគររាជគ្រឹះ ឯភ្នំឈ្មោះវេបុល្ល ជាទីនៅរបស់កុម្ភីរយក្សនោះ មានយក្សជាង១សែននាក់ តែងចូលទៅសេពគប់នឹងកុម្ភីរយក្សនោះ កុម្ភីរយក្សដែលកើតក្នុងនគររាជគ្រឹះ

*នោះ ( ព្រមទាំងបរិវារ ) ក៏មកកាន់មហាវ័នជាទីប្រជុំ ( នៃភិក្ខុទាំងឡាយដែរ ) ។*

បុរិមញ្ច ទិសំ រាជា ធតរដ្ឋោ បសាសតិ។
គន្ធព្វានំ អធិបតិ មហារាជា យសស្សិសោ។

*ព្រះបាទធតរដ្ឋៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងកើត ទ្រង់ជាធំ លើគន្ធព្វទាំងឡាយ ព្រះអង្គជាមហារាជមានយសធំ ។*

បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។

*ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទធតរដ្ឋៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

ទក្ខិណញ្ច ទិសំ រាជា វិរូឡ្ហោ តំ បសាសតិ
កុម្ភណ្ឌានំ អធិបតិ មហារាជា យសស្សិសោ។

*ព្រះបាទ វិរូឡ្ហៈ ទ្រង់ប្រៀនប្រដៅ ក្នុងទិសខាងត្បូង ជាធំលើពួកកុម្ភណ្ឌ ព្រះអង្គជាមហារាជ មានយសធំ ។*

បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។

*ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទវិរូឡ្ហៈនោះ មានច្រើន រូប មានទាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

បច្ឆិមញ្ច ទិសំ រាជា　　វិរូបក្ខោ បសាសតិ
នាគានញ្ច អធិបតិ　　មហារាជា យសស្សិសោ។

*ព្រះបាទវិរូបក្ខៈ ទ្រង់ប្រៀនប្រដៅ ក្នុងទិសខាងលិច ទ្រង់ជាធំលើពួកនាគ ព្រះអង្គជាមហារាជ មានយសធំ ។*

បុត្តាបិ តស្ស ពហវោ　　ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ　　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　　ភិក្ខូនំ សមិតឹ វនំ។

*ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទវិរូបក្ខៈនោះ មាន ច្រើនរូប មានទាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

ឧត្តរញ្ច ទិសំ រាជា　　កុវេរោ តំ បសាសតិ
យក្ខានញ្ច អធិបតិ　　មហារាជា យសស្សិសោ។

*ព្រះបាទកុវេរៈ ទ្រង់ប្រៀនប្រដៅ ក្នុងទិសខាងជើងនោះ ទ្រង់ ជាធំលើពួកយក្ស ព្រះអង្គជាមហារាជ មានយសធំ ។*

បុត្តាបិ តស្ស ពហវោ　　ឥន្ទនាមា មហព្វលា

ឥទ្ធិមន្តោ ជុតិមន្តោ    វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតឹ វនំ។

*ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទកុវេរៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

បុរិមំ ទិសំ ធតរដ្ឋោ    ទក្ខិណេន វិរូឡ្ហកោ
បច្ឆិមេន វិរូបក្ខោ    កុវេរោ ឧត្តរំ ទិសំ។
ចត្តារោ តេ មហារាជា    សមន្តា ចតុរោ ទិសា
ទទ្ទល្លមានា អដ្ឋំសុ    វនេ កាបិលវត្ថវេ។

*ព្រះបាទធតរដ្ឋៈ ជាធំក្នុងទិសខាងកើត ព្រះបាទវិរូឡ្ហកៈ ជាធំក្នុងទិសខាងត្បូង ព្រះបាទវិរូបក្ខៈជាធំ ក្នុងទិសខាងលិច ព្រះបាទកុវេរៈជាធំ ក្នុងទិសខាងជើង មហារាជទាំង ៤ ព្រះអង្គនោះ បានញ៉ាំងទិសទាំង ៤ ដោយជុំវិញឲ្យភ្លឺព្រោងព្រាត ( ដោយរស្មីរបស់ខ្លួន ) ស្ថិតនៅក្នុងព្រៃមហាវ័ន ជិតក្រុងកបិលវត្ថុ ។*

តេសំ មាយាវិនោ ទាសា  អាគុំ វញ្ចនិកា សឋា
មាយា កុដេណ្ឌុ វិដេណ្ឌុ  វិដុច្ច វិដុដោ សហ។
ចន្ទនោ កាមសេដ្ឋោ ច    កិន្និឃណ្ឌុ និឃណ្ឌុ ច
បនាទោ ឱបមញ្ញោ ច    ទេវសូតោ ច មាតលិ។

ចិត្តសេនោ ច គន្ធព្វោ    នឡោរាជា ជនេសភោ
អាគា បញ្ចសិខោ ចេវ    តិម្ពរូ សុរិយវច្ចសា ។

*ពួកទាសៈនៃមហារាជទាំង ៤ ព្រះអង្គនោះ គឺ កុដេណ្ឌុ ១ វិដេណ្ឌុ ១ វិដុច្ចៈ ១ វិដុដៈ ១ ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្និឃណ្ឌុ ១ និឃណ្ឌុ ១ សុទ្ធតែជាអ្នកមានមាយា ជាអ្នកល្បួងបញ្ឆោត ជាអ្នកអួតអាង តែងធ្វើនូវមាយាមក ជាមួយគ្នាដែរ ។*

*ទាំងទេវរាជអម្បាលនេះ គឺ បនាទៈ ១ ឱបមញ្ញៈ ១ ទេវសូត ១ មាតលី ១ ចិត្តគន្ធព្វ ១ សេនគន្ធព្វ ១ ចិត្តសេនគន្ធព្វ ១ នឡការទេវបុត្រ ១ ជវនេសភយក្ស ១ បញ្ចសិខៈ ១ តិម្ពរុ ១ នាងសុរិយវច្ចសា (ជាធីតារបស់តិម្ពរុនោះ ) ១ ក៏នាំគ្នាមកដែរ ។*

ឯតេ ចញ្ញេ ច រាជានោ    គន្ធព្វា សហ រាជុភិ
មោទមានា អភិក្កាមុំ    ភិក្ខូនំ សមិតិំ វនំ។

*គន្ធព្វរាជទាំងឡាយនេះផង ពួកដទៃផង ព្រមទាំងទេវរាជទាំងឡាយ មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

អថាគុំ នាគសា នាគា    វេសាលា សហតច្ឆកា
កម្ពលស្សតរា អាគុំ    ចាយាគា សហ ញាតិភិ។

មួយទៀត នាគទាំងឡាយនៅក្នុងស្រះ ឈ្មោះ នាគសៈ និងនាគនៅក្នុងក្រុងវេសាលី ក៏នាំគ្នាមកជាមួយនឹងនាគបរិស័ទ ឈ្មោះ តច្ឆកៈ កម្ពលនាគ និងអស្សតរនាគ ( ដែលនៅនាជើងភ្នំសិនេរុ) ក៏នាំគ្នាមក នាគទាំងឡាយ នៅក្នុងកំពង់បយាគៈ ព្រមដោយពពួកញាតិ ក៏បាននាំគ្នាមកដែរ ។

យាមុនា ធតរដ្ឋា ច         អាគូ នាគា យសស្សិនោ
ឯរាវណោ មហានាគោ    សោបាគា សមិតិំ វនំ។

ពួកនាគដែលនៅក្នុងទន្លេយមុនាក្តី នាគដែលកើតក្នុងត្រកូលស្តេចធតរដ្ឋៈ មានបរិវារដ៏ច្រើនក្តី ក៏បាននាំគ្នាមក សូម្បីតែឯរាវ៉ាណទេវបុត្រ ជាដំរីធំនោះសោត ក៏បានមកកាន់ព្រៃមហាវ័នជាទីប្រជុំ (នៃភិក្ខុទាំងឡាយដែរ) ។

យេ នាគរាជេ សហសា ហរន្តិ
ទិព្វា ទិជា បក្ខិ វិសុទ្ធចក្ខូ
វេហាយសា តេ វនមជ្ឈបត្តា
ចិត្រា សុបណ្ណា ឥតិ តេស នាមំ។

ពួកគ្រុឌណា ជាសត្វស្លាបមានកំណើតពីរដង មានអានុភាពជាទិព្វ មានភ្នែកដ៏បរិសុទ្ធ ( អាចមើលឃើញនូវពួកនាគអំពីចម្ងាយ ចំនួន ១០០ យោជន៍ ១០០០យោជន៍ ) តែងចាប់យកនូវស្តេចនាគ ទៅដោយឆាប់រហ័ស គ្រុឌទាំង

នោះ ក៏ហើរមកតាមអាកាស បានមកដល់ពាក់កណ្តាលនៃព្រៃមហាវ័ន គ្រុឌទាំងនោះមានឈ្មោះថា ចិត្រសុបណ្ណៈដូច្នេះ។

អភយំ តទា នាគានមាសិ
សុបណ្ណតោ ខេមមកាសិ ពុទ្ធោ
សណ្ហាហិ វាចាហិ ឧបវ្ហយន្តា
នាគា សុបណ្ណា សរណមកំសុ ពុទ្ធំ។

គ្រានោះ ស្តេចនាគទាំងឡាយ ក៏មិនមានសេចក្តីភ័យខ្លាចឡើយ ព្រះសម្ពុទ្ធជាម្ចាស់ ក៏បានធ្វើ ( ស្តេចនាគ ) ឲ្យក្សេមក្សាន្តអំពីគ្រុឌ នាគនិងគ្រុឌទាំងឡាយ ក៏ត្រឡប់និយាយរកគ្នា ដោយសម្តីដ៏ពីរោះ ( ហាក់ដូចជាមិត្តសំឡាញ់នឹងគ្នា ) បានធ្វើនូវព្រះពុទ្ធឲ្យជាទីពឹងទីរលឹក ។

ជិតា វជិរហត្ថេន　　　　សមុទ្ទំ អសុរាសិតា។
ភាតរោ វាសវស្សេតេ　　　　ឥទ្ធិមន្តោ យសស្សិនោ។

ពួកអសុរ ( ណា ) ដែលព្រះឥន្ទ្រឈ្នះហើយ អាស្រ័យនៅក្នុងសមុទ្រ ពួកអសុរទាំងនោះ ជាបងប្អូន ( ជាប់ពន្ធ ) នឹងព្រះឥន្ទ្រ ជាអ្នកមានឫទ្ធិ មានយស ។

កាលកញ្ចា មហាភិស្មា　　　　អសុរា ទានវេឃសា
វេបចិត្តិ សុចិត្តិ ច　　　　បហារាទោ នមុចី សហ។

កាលកញ្ចអសុរទាំងឡាយ មានកាយធំ សម្បើមក្តី ទានវេឃសអសុរទាំងឡាយក្តី វេបចិត្តិអសុរក្តី សុចិត្តិអសុរក្តី បហារាទអសុរក្តី នមុចីទេវបុត្តមារក្តី ក៏មកជាមួយគ្នាដែរ ។

សតញ្ច ពលិបុត្តានំ　　សព្វេ វេរោចនាមកា
សន្នយ្ហិត្វា ពលិសេនំ　　រាហុភទ្ទមុបាគមុំ
សមយោទានិ ភទ្ទន្តេ　　ភិក្ខូនំ សមិតឹ វនំ។

*កូនរបស់ពលិអសុរទាំង ១០០ នាក់ មាន ឈ្មោះថា វេរោចៈ ទាំងអស់ ចងសៀតនូវគ្រឿងពលិសេនា ចូលមកគាល់រាហុ អសុរិន្ទដ៏ចម្រើន ដោយពាក្យថា ឥឡូវនេះ ជាសម័យគួរ នឹងប្រជុំគ្នា សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ដូច្នេះហើយ ទេវតាទាំងនោះ ដ៏នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃ ភិក្ខុទាំងឡាយ ។*

អាបោ ច ទេវា បឋវី　　តេជោ វាយោ តទាគមុំ
វរុណា វារុណា ទេវា　　សោមោ ច យសសា សហ។

*អាបោទេវតាក្តី បឋវិទេវតាក្តី តេជោទេវតាក្តី វាយោទេវតាក្តី វរុណទេវតាក្តី វារុណទេវតាក្តី សោមទេវតា ព្រមទាំង យសទេវតាក្តី ក៏បាននាំគ្នាមកដែរ ។*

មេត្តា ករុណា កាយិកា　　អាគុំ ទេវា យសស្សិនោ
ទសេតេ ទសធា កាយា　　សព្វេ នានត្តវណ្ណិនោ។
ឥទ្ធិមន្តោ ជុតិមន្តោ　　វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ　　ភិក្ខូនំ សមិតឹ វនំ។

*ទេវតាទាំងឡាយ ដែលកើតដោយអំណាចមេត្តាឈាននិង ករុណាឈាន ជាអ្នកមានយស ក៏បាននាំគ្នាមក ទេវតាទាំង ១០*

ពួកនេះ ឋិតនៅដោយចំណែក ១០ សុទ្ធតែ មានសម្បុរផ្សេង ៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

វេណ្ឌុទេវា សហលិ ច អសមា ច ទុវេ យមា
ចន្ទស្សូបនិសា ទេវា ចន្ទមាគុំ បុរក្ខត្វា ។

ពួកទេវតា ឈ្មោះវេណ្ឌុក្ដី ឈ្មោះសហលីក្ដី ឈ្មោះអសមាក្ដី និងឈ្មោះយមកៈទាំងពីរក្ដី ពួកទេវតដែលអាស្រ័យនូវក្នុងស្ថានព្រះចន្ទក្ដី បានហែហមចន្ទទេពក៏មកដែរ ។

សូរិយស្សូបនិសា ទេវា សូរិយមាគុំ បុរក្ខត្វា
នក្ខត្តានិ បុរក្ខត្វា អាគុំ មន្ទវលាហកា ។

ពួកទេវតាដែលអាស្រ័យនៅស្ថានព្រះអាទិត្យ បានហែហមសុរិយទេពមក ពួកទេវតាដែលអាស្រ័យនៅពិកពផ្កាយ ក៏ហែហមនក្ខត្តទេពមក ទាំងមន្ទវលាហកទេវតាទាំងឡាយក៏មក ។

វសុនំ វាសវោ សេដ្ឋោ សក្កោបាគា បុរិន្ទទោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ ។
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ ។

សូម្បីសក្កទេវរាជ ទ្រង់ព្រះនាមវាសវបុរិន្ទទៈ ដ៏ប្រសើរជាងពួកទេវតាក៏មកដែរ ទេវតាទាំង ១០ ពួកនេះ ស្ថិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នា ទាំងអស់ មានឫទ្ធិ

*មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

"អថាគុំ សហភូ ទេវា ជលមគ្គិសិខារិវ
អរិដ្ឋកា ច រោជា ច ឧមាបុប្ផនិភាសិនោ។
"វរុណា សហធម្មា ច អច្ចុតា ច អនេជកា
សូលេយ្យរុចិរា អាគុំ អាគុំ វាសវនេសិនោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ។
"ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។

*មួយទៀត ទេវតាទាំងឡាយ ឈ្មោះសហភូទេពដ៏រុងរឿង បីដូចជាអណ្តាតភ្លើង ក៏បានមក ពួកទេវតាឈ្មោះ អរិដ្ឋកទេពក្តី រោជទេពក្តី ឧមាបុប្ផទេពក្តី វរុណទេពក្តី សហធម្មទេពក្តី អច្ចុតទេពក្តី អនេជកទេពក្តី សុលេយ្យទេពក្តី រុចិរទេពក្តី ក៏បានមក ទាំងពួកទេវតាឈ្មោះវាសវនេសីក៏បានមក ។*

*ទេវតាទាំង ១០ ពួកនេះ ស្ថិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មាន យស មានចិត្តរីករាយ ក៏នាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

សមានា មហាសមនា មានុសា មានុសុត្តមា
ខិឌ្ឌាបទោសិកា អាគុំ អាគុំ មនោបទោសិកា។

"អថាគុំ ហរយោ ទេវា យេ ច លោហិតវាសិនោ
បារគា មហាបារគា អាគុំ ទេវា យសស្សិនោ
ទសេតេ ទសធា កាយា សព្វេ នានត្តវណ្ណិនោ។

*ទេវតាទាំងឡាយ ឈ្មោះសមានៈក្តី មហាសមានៈក្តី មានុសៈក្តី មានុសុត្តមៈក្តី ខិឌ្ឌាបទូសិកៈក្តី ក៏បានមក ពួកទេវតា ឈ្មោះមនោបទូសិកៈ ក៏បានមក ទាំងពួកទេវតាឈ្មោះហរិក្តី ឈ្មោះលោហិតវាសីក្តី ក៏បានមក ទេវតាទាំងឡាយ ឈ្មោះ បារគៈក្តី ឈ្មោះមហាបារគៈក្តី ជាអ្នកមានយសក៏បានមក ។*

ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតិំ វនំ។

*ទេវតាទាំង ១០ ពួកនេះ ស្ថិតនៅដោយចំណែក ១០ សុទ្ធតែមាន សម្បុរផ្សេង ៗ គ្នា ទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

សុក្កា ករម្ភា អរុណា អាគុំ វេឃនសា សហ
ឱទាតគយ្ហា បាមោក្ខា អាគុំ ទេវា វិចក្ខណា។
សទាមត្តា ហារគជា មិស្សកា ច យសស្សិនោ
ថនយំ អាគ បជ្ជុន្នោ យោ ទិសា អភិវស្សតិ។

*ទេវតាទាំងឡាយ ឈ្មោះសុក្កៈក្តី ករម្ភៈក្តី អរុណៈក្តី ក៏បានមក ជាមួយនឹងវេឃនសទេវតា ។ ពួកទេវតាឈ្មោះឱទាតគយ្ហៈ*

*ជាប្រធានក្តី ឈ្មោះវិចក្ខណៈក្តី ក៏បានមកពួកទេវតា ឈ្មោះសទាមត្តៈក្តី ឈ្មោះហារគជៈក្តី ឈ្មោះមិស្សកៈក្តី សុទ្ធតែជាអ្នកមានយស ( ក៏បានមក ) បជ្ជុន្នទេវរាជ ដែលញ៉ាំងមេឃឲ្យគ្រហឹម កម្ទរ ហើយបង្អុរភ្លៀងឲ្យធ្លាក់ចុះ គ្រប់ទិសក៏បានមក ។*

ឧសោតេ ឧសធា កាយា សព្ទេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ ភិក្ខូនំ សមិតឹ វនំ។

*ទេវតាទាំង ១០ ពួកនេះ ឋិតនៅ ដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

ខេមិយា តុសិតា យាមា កដ្ឋកា ច យសស្សិនោ
លម្ពីតកា លាមសេដ្ឋា ជោតិនាមា ច អាសវា
និម្មានរតិនោ អាគុំ អថាគុំ បរនិម្មិតា។

*ពួកខេមិយទេវតា ដែលស្ថិតនៅក្នុងតុសិតបុរីក្តី ស្ថិតនៅក្នុងយាមទេវលោកក្តី ពួកកដ្ឋកទេវតាដែលមានយសក្តី ពួកលម្ពិតកទេវតាក្តី ពួកលាមសេដ្ឋទេវតាក្តី ពួកទេវតាឈ្មោះជោតិក្តី ឈ្មោះអាសវៈក្តី ពួកនិម្មានរតីទេវតាក្តី ក៏បានមក ទាំងពួកបរនិម្មិតទេវតា ក៏បានមក ។*

ឧសោតេ ឧសធា កាយា សព្ទេ នានត្តវណ្ណិនោ

ឥទ្ធិមន្តោ ជុតិមន្តោ	វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ	ភិក្ខូនំ សមិតិំ វនំ។

*ទេវតាទាំង ១០ ពួកនេះ ស្ថិតតនៅដោយចំណែក ១០ សុទ្ធតែ មានសម្បុរផ្សេង ៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់ព្រៃមហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

សដ្ឋេតេ ទេវនិកាយា	សព្វេ នានត្តវណ្ណិនោ
នាមន្វយេន អាគច្ឆុំ	យេ ចញ្ញេ សទិសា សហ។
បវុដ្ឋជាតិមខិលំ	ឱឃតិណ្ណមនាសវំ
ទក្ខេមោឃ តរំ នាគំ	ចន្ទំវ អសិតាតិគំ។

*ពួកទេវតាទាំង ៦០ មាន អាបោទេវតាជាដើមនេះ សុទ្ធតែមាន សម្បុរផ្សេង ៗ គ្នាទាំងអស់ មកហើយដោយ ចំណែកនាម សូម្បីពួកទេវតាណាក្រៅពីនោះ ដែលមានរស្មីប្រហែលគ្នា ក៏មកព្រមគ្នាដោយគិតថា យើងទាំងឡាយនឹងទៅមើលព្រះអរិយសង្ឃ ដែលប្រាសចាកជាតិ ឥតមានកិលេស ដូចជាដែកគោល លោកឆ្លងចាកអន្លង់ទាំង ៤ ហើយ មិនមានកិលេសជាគ្រឿងត្រាំ រួចស្រឡះចាកឱឃៈទាំង ៤ ហើយ លោកមិនបានធ្វើនូវបាប មួយទៀត យើងនឹងបានឃើញនូវព្រះទសពល ដែលរុងរឿង ដោយសិរី ដូចព្រះចន្ទឆ្លងផុតអំពីពពក ។*

សុព្រហ្មា បរមត្តោ ច	បុត្តា ឥទ្ធិមតោ សហ
សនង្កុមារោ តិស្សោ ច	សោបាគ សមិតិំ វនំ។

*អរិយព្រហ្មទាំងឡាយ គឺ សុព្រហ្ម និងបរមត្តព្រហ្ម ជាបុត្តរបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានឫទ្ធិ ក៏មកជាមួយគ្នា សនង្កុមារមហាព្រហ្មក្តី តិស្សមហាព្រហ្មក្តី ក៏នាំគ្នាមកកាន់ព្រៃមហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។*

សហស្សំ ព្រហ្មលោកានំ  មហាព្រហ្មាភិតិដ្ឋតិ
ឧបបន្នោ ជុតិមន្តោ  ភិស្មាកាយោ យសស្សិសោ ។

*មហាព្រហ្មទាំង ១ ពាន់ ក៏មកហើយ មហាព្រហ្ម ១ អង្គ គ្របសង្កត់នូវព្រហ្ម ឯទៀតបាន មហាព្រហ្មនោះ កើតក្នុងព្រហ្មលោកមានអានុ ភាព មានកាយសម្បើម មានយស ក៏មកដែរ ។*

ធសេត្ថ ឥស្សរា អាគុំ  បច្ចេកវសវត្តិនោ
តេសញ្ច មជ្ឈតោ អាគ  ហារិតោ បរិវារិតោ ។

*មហាព្រហ្ម ទាំង ១០ ជាឥស្សរៈលើព្រហ្មទាំង ១ ពាន់នេះ តែងផ្សាយ អំណាចផ្សេង ៗ ក៏បានមក ហារិតមហាព្រហ្ម ( ដែលមានព្រហ្មទាំង ១ សែន ) ហែហមក្នុងកណ្តាលនៃពួកព្រហ្មទាំងនោះក៏បានមក ។*

តេ ច សព្វេ អភិក្កន្តេ  សឥន្ទេ ទេវេ សព្រហ្មកេ
មារសេនា អភិក្កាមិ  បស្ស កណ្ហស្ស មន្ទិយំ ។

*សេនារបស់មារបានឃើញនូវពួកទេវតា ព្រមទាំងព្រះឥន្ទ ព្រមទាំងព្រះព្រហ្មទាំងអស់នោះមកជួបជុំហើយ ក៏បានមក ហើយពោលថា អ្នកទាំងឡាយ ចូរមើលនូវសេចក្តីល្ងង់នៃមារ ។*

ឯថ គណ្ហថ ពន្ធថ　　　　រាគេន ពន្ធមត្ថុ វោ
សមន្តា បរិវារេថ　　　　មា វោ មុញ្ចិត្ថ កោចិ នំ ។

ឯសេនារបស់មារក៏ពោលថា ) អ្នកទាំងឡាយចូរមក ចូរចាប់ចងពួកទេវតាទាំងនេះទុក ការចងដោយរាគៈ ចូរមានដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរព័ទ្ធឲ្យជុំវិញ បណ្ដាអ្នកទាំងអស់គ្នា អ្នកណាមួយក៏កុំបណ្ដោយឲ្យទេវតា ១ អង្គ រួចទៅបានឡើយ ។

ឥតិ តត្ថ មហាសេនោ　　　　កណ្ហោ សេនំ អបេសយិ;
ចាណិនា តលមាហច្ច　　　　សរំ កត្វាន ភេរវំ ។
យថា ចាវុស្សកោ មេឃោ　　　　ថនយន្តោ សវិជ្ជុកោ
តទា សោ បច្ចុទាវត្តិ　　　　សង្កុទ្ធោ អសយំវសេ ។

មារជាសេនាធំក្នុងទីប្រជុំធំនោះ ក៏ទះនូវផ្ទៃនៃផែនដីដោយបាតដៃ ធ្វើនូវសំឡេងគំរាមមុខគួរខ្លាច ដូចជាមហាមេឃ គ្រហឹម បង្អុរភ្លៀងមានទាំងផ្លេកបន្ទោរ ក្នុងកាលនោះ មារនោះ មិនអាចនឹងធ្វើ ( ទេវតាណាមួយ ) ឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនបាន ក៏ក្រេវក្រោធថយចេញបាត់ទៅ ។

តញ្ច សព្វំ អភិញ្ញាយ　　　　វវត្ថិត្វាន ចក្ខុមា
តតោ អាមន្តយី សត្ថា　　　　សាវកេ សាសនេ រតេ ។

លំដាប់នោះព្រះសាស្ដា ទ្រង់មានចក្ខុ ពិចារណាហើយ ជ្រាបហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់នឹងភិក្ខុជាសាវកទាំងឡាយ ដែលត្រេកអរក្នុងសាសនាថា

មារសេនា អភិក្កន្តា តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមករុំ សុត្វា ពុទ្ធស្ស សាសនំ
វីតរាគេហិ បក្កាមុំ នេសំ លោមាបិ ឥញ្ជយុំ ។

*ម្នាលភិក្ខុទាំងឡាយ មារសេនាមកដល់ហើយ អ្នកទាំងឡាយ ចូរស្គាល់នូវមារសេនាទាំងនោះចុះ ឯពួកភិក្ខុទាំងនោះ លុះបានស្តាប់ពាក្យប្រដៅព្រះពុទ្ធ ជាម្ចាស់ហើយ ក៏ធ្វើព្យាយាម ( ដើម្បីចូលកាន់ផលសមាបត្តិ ) ។ មារព្រមទាំងពួកសេនារបស់មារ ក៏ចៀសចេញឆ្ងាយទៅ អំពីពួកអរិយសាវ័កដែលប្រាសចាករាគៈ សូម្បីតែរោមរបស់ព្រះអរិយៈទាំងនោះ ក៏មិនបានព្រឺព្រួចឡើយ ។*

សព្វេ វិជិតសង្គាមា ភយាតីតា យសស្សិនោ
មោទន្តិ សហ ភូតេហិ សាវកា តេ ជនេសុតាតិ ។

*(ទើបមារពោលសរសើរភិក្ខុសង្ឃថា ) ពួកសាវ័កទាំងនោះ លោកឈ្នះសឹកសង្គ្រាមហើយ កន្លងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយសល្បីទូរទ័រទៅក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈដែលកើតហើយ ( ក្នុងសាសនាព្រះទសពល ) ។*

មហាសមយសុត្តំ និដ្ឋិតំ ។

មហាសមយសូត្រ ចប់ត្រឹមប៉ុណ្ណោះឯង ។

# សម្មាបរិព្វាជនីយសូត្រ

## ពួកទេវតានិងមនុស្សជាពាលចរិត

## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/១១៤)

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

បុច្ឆាមិ មុនឹ បហូតបញ្ញំ
តិណ្ណំ បារង្គតំ បរិនិព្វុតំ ឋិតត្តំ
និក្ខម្ម ឃរា បនុជ្ជ កាមេ  កថំ
ភិក្ខុ  សម្មា សោ លោកេ បរិព្វជេយ្យ។

*ខ្ញុំសូមសួរនូវព្រះមុនី ដែលមានប្រាជ្ញាច្រើន*
*បានឆ្លងចាកឱឃៈ ( ដល់នូវត្រើយ គឺព្រះនិព្វាន )*
*បានរំលត់ហើយ មានព្រះទ័យតាំងនៅមាំ*
*ភិក្ខុបន្ទោបង់នូវកាមទាំងឡាយ ហើយ*
*ចេញចាកផ្ទះ ភិក្ខុនោះឈ្មោះថាវៀរដោយ*
*ប្រពៃក្នុងលោក តើដោយប្រការដូចម្ដេច? ។*

( *ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

យស្ស មង្គលា សមូហតា
ឧប្បាតា សុបិនា ច លក្ខណា ច
សោ មង្គលទោសវិប្បហីនោ
សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុណាបានគាស់រំលើងនូវមង្គលផង*

*នូវការប្រកាន់ឧប្បាត ( មានរន្ទះបាញ់ជាដើម ) ផង*
*នូវការប្រកាន់យល់សប្តិផង នូវការប្រកាន់*
*លក្ខណៈផង ភិក្ខុនោះ ឈ្មោះថា បានលះបង់ស្រឡះ*
*នូវមង្គលជាទោស  ភិក្ខុនោះ ឈ្មោះថា វៀរដោយ*
*ប្រពៃក្នុងលោក ។*

រាគំ វិនយេថ មានុសេសុ
ទិព្វេសុ កាមេសុ ចាបិ ភិក្ខុ
អតិក្កម្ម ភវំ សមេច្ច ធម្មំ
សម្មា សោ លោកេ បរិព្វជេយ្យ ។

*ភិក្ខុបន្ទោបង់នូវតម្រេក ក្នុងកាមទាំងឡាយ*
*ជារបស់មនុស្សផង  របស់ទេវតាផង*
*កន្លងនូវភព បានត្រាស់ដឹងនូវធម៌ ភិក្ខុនោះ ឈ្មោះថា*
*វៀរដោយប្រពៃ ក្នុងលោក ។*

វិបិដ្ឋិកត្វាន បេសុណានិ
កោធំ កទរិយំ ជហេយ្យ ភិក្ខុ
អនុរោធវិរោធវិប្បហីនោ
សម្មា សោ លោកេ បរិព្វជេយ្យ ។

*ភិក្ខុធ្វើចិត្តមិនឲ្យត្រេកអរ លះនូវពាក្យញុះញង់*
*ទាំងឡាយ នូវសេចក្តីក្រោធនិងសេចក្តីកំណាញ់*

*លះនូវរាគៈ និងទោសៈ ភិក្ខុនោះ ឈ្មោះថា*
*វៀរដោយប្រពៃក្នុងលោក ។*

ហិត្វាន បិយញ្ច អប្បិយញ្ច
អនុបាទាយ អនិស្សិតោ កុហិញ្ចិ
សំយោជនិយេហិ វិប្បមុត្តោ
សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុលះបង់នូវសេចក្ដីស្រឡាញ់ និងស្អប់ មិនប្រកាន់មាំ មិនអាស្រ័យក្នុងសភាវៈតិចតួច ( ដោយតណ្ហា និងទិដ្ឋិ ) ឡើយ មានចិត្តផុតស្រឡះហើយ ចាកសំយោជនិយធម៌ទាំងឡាយ (ធម៌ជាអារម្មណ៍នៃសំយោជនៈ ) ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។*

ន សោ ឧបធីសុ សារមេតិ
អាទានេសុ វិនេយ្យ ឆន្ទរាគំ
សោ អនិស្សិតោ អនញ្ញនេយ្យោ
សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុនោះ បន្ទោបង់នូវឆន្ទរាគៈ ក្នុងខន្ធជាគ្រឿងប្រកាន់ មិនដល់ (នូវការឃើញ ) ថាមានខ្លឹមក្នុងឧបធិ គឺខន្ធទាំងឡាយនោះ ជាបុគ្គលមិនអាស្រ័យ ( ដោយឆន្ទៈ និងរាគៈ ) មិនបាច់មានបុគ្គលដទៃណែនាំឡើយ*

ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

វចសា មនសា ច កម្មុនា ច
អវិរុទ្ធោ សម្មា វិទិត្វា ធម្មំ
និព្វានបទាភិបត្ថយានោ
សម្មា សោ លោកេ បរិព្វជេយ្យ។

ភិក្ខុមិនភ្លាត់ខុសដោយកាយ វាចា និងចិត្ត ដឹងច្បាស់នូវធម៌ដោយប្រពៃ ប្រាថ្នាយកនូវបទ គឺព្រះនិព្វាន ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

យោ វន្ទតិ មន្តិ នុណ្ណមេយ្យ
អក្កុដ្ឋោបិ ន សន្ធិយេថ ភិក្ខុ
លទ្ធា បរភោជនំ ន មជ្ជេ
សម្មា សោ លោកេ បរិព្វជេយ្យ។

ភិក្ខុណាមិនក្រអឺតក្រឱង ដោយគិតថា គេថ្វាយបង្គំ អញ   សូម្បីគេជេរក៏មិនតបត បាននូវភោជន របស់អ្នកដទៃឲ្យ ក៏មិនស្រវឹង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

លោកញ្ច ភវញ្ច វិប្បហាយ
វិរតោ ជេទនពន្ធនា ច ភិក្ខុ
សោ តិណ្ណកថំកថោ វិសល្លោ

សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុលះបង់សេចក្តីលោភ និងភព វៀរចាកការ កាប់កាត់ និងការចង ( សត្វដទៃ ) ភិក្ខុនោះ ជាអ្នក ចូងចាកសេចក្តីងឿងឆ្ងល់ ប្រាសចាកសរ គឺសេចក្តី សោក ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។*

សារុប្បំ អត្តនោ វិទិត្វា

នោ ច ភិក្ខុ ហឹសេយ្យ កញ្ចិ លោកេ

យថា តថិយំ វិទិត្វា ធម្មំ

សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុណាបានដឹងច្បាស់នូវសេចក្តីប្រព្រឹត្តដ៏សមគួរ របស់ខ្លួនផង មិនបៀតបៀនជនដទៃណាមួយ ក្នុងលោកផង ដឹងច្បាស់នូវធម៌តាមសេចក្តីពិត ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។*

យស្សានុសយា ន សន្តិ កេចិ

មូលា ច អកុសលា សមូហតាសេ

សោ និរាសោ អនាសិសានោ

សម្មា សោ លោកេ បរិព្វជេយ្យ។

*អនុស័យទាំងឡាយណាមួយ មិនមានដល់ភិក្ខុណា អកុសលមូលទាំងឡាយ ភិក្ខុណាបានដក*

ចោលហើយ ភិក្ខុនោះ ជាអ្នកមិនមាន
សេចក្តីប្រាថ្នា មិនមានសេចក្តីអាឡោះអាល័យ
ភិក្ខុនោះ ឈ្មោះថា  វៀរដោយប្រពៃក្នុងលោក ។

អាសវខីណោ បហីនមានោ
សព្វំ រាគបថំ ឧបាតិវត្តោ
ទន្តោ បរិនិព្វុតោ ឋិតត្តោ
សម្មា សោ លោកេ បរិព្វជេយ្យ។

ភិក្ខុអ្នកអស់អាសវៈហើយ លះបង់នូវមានះ
កន្លងផុតនូវធម៌ ជាគន្លងនៃរាគៈទាំងអស់
ទូន្មានខ្លួន សម្រេចនូវព្រះនិព្វាន មានចិត្ត
តាំងនៅមាំ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ
ក្នុងលោក ។

សទ្ធោ សុតវា និយាមទស្សី
វគ្គគតេសុ ន វគ្គសារិ ធីរោ
លោភំ ទោសំ វិនេយ្យ បដិឃំ
សម្មា សោ លោកេ បរិព្វជេយ្យ។

ភិក្ខុអ្នកមានសទ្ធាប្រកបដោយសុតៈ
ប្រព្រឹត្តទៅក្នុងបរមត្ថ បានឃើញសម្មត្តនិយាម គឺមគ្គ
កាលពួកសត្វប្រព្រឹត្តទៅដោយទិដ្ឋិ ៦២ ក៏មិនប្រព្រឹត្ត
ទៅដោយពួក ជាអ្នកប្រាជ្ញ អាចបន្ទោបង់នូវលោភៈ

ទោសៈ និងសេចក្តីថ្នាំងថ្នាក់ ភិក្ខុនោះ
ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។
សំសុទ្ធជិនោ វិវដ្ដច្ឆទោ
ធម្មេសុ វសី បារគូ អនេជោ
សង្ខារនិរោធញាណកុសលោ
សម្មា សោ លោកេ បរិព្វជេយ្យ។
ភិក្ខុបានឈ្នះកិលេស ដោយអរហត្តមគ្គដ៏បរិសុទ្ធ
បើកបេញនូវកិលេសជាគ្រឿងប្រក់ ជាអ្នកស្ទាត់
ក្នុងចតុស្សច្ចធម៌ ដល់នូវត្រើយ គឺព្រះនិព្វាន
មានសន្តានមិនរំភើបដោយតណ្ហា ជាអ្នកឈ្លាសវៃ
ក្នុងអរិយមគ្គ គ្រឿងដឹងនូវធម៌ជាទីរលត់នៃសង្ខារ
ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។
អតីតេសុ អនាគតេសុ ចាបិ
កប្បាតីតោ អតិច្ចសុទ្ធិបញ្ញោ
សព្វាយតនេហិ វិប្បមុត្តោ
សម្មា សោ លោកេ បរិព្វជេយ្យ។
ភិក្ខុកន្លងនូវកប្បៈ គឺតណ្ហា និងទិដ្ឋិ ក្នុងខន្ធទាំងឡាយ
ដែលជាអតីតៈនិងអនាគត ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ
ព្រោះកន្លងផុត ( នូវអទ្ធា ៣ ) មានចិត្តផុតស្រឡះ
ចាកអាយតនៈទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរ
ដោយប្រពៃក្នុងលោក ។

អញ្ញាយ បជំ សមេច្ច ធម្មំ
វិវដំ ធិស្វាន បហានមាសវានំ
សព្វុបធីនំ បរិក្ខយានោ
សម្មា សោ លោកេ បរិព្វជេយ្យ។

*ភិក្ខុកំណត់ដឹងនូវបទ គឺសច្ចៈមួយ ៗ*
*ហើយត្រាស់ដឹងនូវសច្ចៈធម៌ ឃើញនូវព្រះនិព្វាន*
*មិនមានគ្រឿងដោតក្រង ជាទីលះបង់នូវអាសវៈ*
*ទាំងឡាយ ព្រោះអស់ទៅនៃឧបធិក្កិលេសទាំងពួង*
*ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។*

*( ព្រះពុទ្ធនិម្មិតពោលសរសើរថា )*

អទ្ធា ហិ ភគវា តថេវ ឯតំ
យោ សោ ឯវំវិហារី ទន្តោ ភិក្ខុ
សព្វសំយោជនយោគវីតិវត្តោ
សម្មា សោ លោកេ បរិព្វជេយ្យាតិ។

*សេចក្តីពិតថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់*
*ព្រះពុទ្ធដីកាយ៉ាងនេះ មានសេចក្តីបែបនោះដដែលថា*
*ភិក្ខុណាមានការនៅយ៉ាងនេះ ជាអ្នកទូន្មានខ្លួន*
*ប្រព្រឹត្តិកន្លងនូវសំយោជនធម៌ទាំងពួង ភិក្ខុនោះ*
*ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។*

***ចប់ សម្មាបរិព្វាជនីយសូត្រ***

# កលហវិវាទសូត្រ
## ពួកទេវតានិងមនុស្សដែលជាទោសចរិត
## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/២៩០)

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

កុតោបហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
កុតោបហូតា តេ តទិង្ឃ ព្រូហិ ។
*ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល*
*ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់*
*ការមើលងាយ និងការញុះញង់ កើតមកអំពីណា*
*កិលេសធម៌ទាំងនោះ បណ្តាលមកអំពីណា*
*សូមព្រះអង្គសម្តែងសេចក្តីនោះឲ្យទាន ។*

(*ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

បិយប្បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
មច្ឆេរយុត្តា កលហា វិវាទា
វិវាទជាតេសុ ច បេសុណានិ ។

*ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់ កើតមកអំពីរបស់ជាទីស្រឡាញ់ ឯកិលេសធម៌ មានការឈ្លោះនិងការជជែកគ្នា (ជាដើម ) ប្រកបក្នុងសេចក្តីកំណាញ់ កាលបើសេចក្តីទាស់ទែងគ្នាកើតឡើងហើយ ពាក្យញុះញង់ក៏កើតឡើងដែរ ។*

*( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )*

បិយា សុ លោកស្មិំ កុតោនិទានា
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច កុតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តិ។

*សេចក្តីស្រឡាញ់ក្នុងលោក ឬលោភៈរបស់ពួកសត្វដែលត្រូវលោភៈគ្របសង្កត់ រង្គាត់ទៅក្នុងលោក កើតមកអំពីអ្វី សេចក្តីប៉ុនប៉ង និងការសម្រេច ( នៃសេចក្តីប៉ុនប៉ង ) និងធម៌ដែលមានក្នុងបរលោករបស់សត្វ កើតមកអំពីអ្វី ។*

*(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )*

ឆន្ទានិទានានិ បិយានិ លោកេ
យេ ចាបិ លោភា វិចរន្តិ លោកេ

អាសា ច និដ្ឋា ច ឥតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តិ។
*សេចក្ដីស្រឡាញ់ក្នុងលោក ឬលោកៈរបស់ពួកសត្វ*
*ដែលត្រូវលោភៈគ្របសង្កត់ កើតមកអំពីឆន្ទៈ*
*សេចក្ដីប៉ុនប៉ង និងការសម្រេច ( នៃសេចក្ដីប៉ុនប៉ង )*
*និងធម៌ដែលមានក្នុងបរលោករបស់ពួកសត្វ ក៏កើត*
*អំពីឆន្ទៈនេះដែរ ។*

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

ឆន្ទោ នុ លោកស្មឹ កុតោនិទានោ
វិនិច្ឆយា ចាបិ កុតោបហូតា
កោធោ មោសវជ្ជញ្ច កថំកថា ច
យេ វាបិ ធម្មា សមណេន វុត្តា។
*ឆន្ទៈក្នុងលោក កើតមកអំពីអ្វី មួយទៀត វិនិច្ឆ័យ*
*(ការចូលចិត្តក្នុងតណ្ហានិងទិដ្ឋិ ) កើតមកអំពីអ្វី*
*ការក្រេវក្រោធ ការនិយាយមោសា និងសេចក្ដី*
*សង្ស័យ ឬអកុសលធម៌ទាំងឡាយ ដែល ( ប្រកប*
*ដោយការក្រេវក្រោធជាដើម ) តើព្រះសមណៈ*
*សម្ដែងហើយថា កើតអំពីអ្វី ។*

(*ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

សាតំ អសាតន្តិ យមាហុ លោកេ
តម្ហូបនិស្សាយ បហោតិ ឆន្ទោ

រូបេសុ ទិស្វា វិភវំ ភវញ្ច
វិនិច្ឆយំ កុព្វតិជន្តុ លោកេ។
*អ្នកប្រាជ្ញទាំងឡាយក្នុងលោក បានសម្តែងហើយ*
*នូវអារម្មណ៍ណាថា ជាទីត្រេកអរ និងមិនជាទីត្រេកអរ*
*ឆន្ទៈតែងកើតឡើង ព្រោះអាស្រ័យអារម្មណ៍នោះ*
*សត្វក្នុងលោកឃើញសេចក្តីវិនាស និងសេចក្តី*
*ចម្រើន ក្នុងរូបទាំងឡាយ ទើបធ្វើនូវវិនិច្ឆ័យ*
*(ក្នុងតណ្ហានិងទិដ្ឋិ ) ។*
កោធោ មោសវជ្ជញ្ច កថំកថា ច
ឯតេបិ ធម្មា ទ្វយមេវ សន្តេ
កថំកថី ញាណបថាយ សិក្ខេ
ញត្វា បវុត្តា សមណេន ធម្មា។
*ការក្រេវក្រោធ ការពោលពាក្យមោសា សេចក្តី*
*សង្ស័យ ធម៌ទាំង ៣ នេះឯង កាលបើអារម្មណ៍ជាទី*
*ត្រេកអរ និងមិនជាទីត្រេកអរទាំង ២ ប្រការនោះ*
*នៅមាន ទើបកើតមានឡើងបាន បុគ្គលអ្នកមាន*
*សេចក្តីសង្ស័យ គប្បីសិក្សាក្នុងគន្លងនៃការដឹង*
*ឯធម៌ទាំងឡាយ ព្រះសមណៈសម្តែងហើយ*
*ព្រោះដឹង ។*

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

សាតំ អសាតញ្ច កុតោនិទានា

កិស្មិំ អសន្តេ ន ភវន្តិ ហោតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតំ មេ បព្រូហិ យតោនិទានំ។
*អារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ*
*កើតមកអំពីអ្វី កាលបើអ្វីមិនមាន ទើបអារម្មណ៍*
*ទាំងនុ៎ះ មិនមានដែរ អត្ថគឺសេចក្តីវិនាស និងសេចក្តី*
*ចម្រើន ( នៃអារម្មណ៍ជាទីត្រេកអរ និងមិនជាទី*
*ត្រេកអរ ) ណា អត្ថនោះ តើកើតមកអំពីធម៌ណា*
*សូមព្រះអង្គសម្តែងប្រាប់ដល់ខ្ញុំ ឲ្យទាន ។*

*(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )*

ផស្សនិទានំ សាតំ អសាតំ
ផស្សេ អសន្តេ ន ភវន្តិ ហោតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតំ តេ បព្រូមិ ឥតោនិទានំ។
*អារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេកអរ កើតមក*
*អំពីផស្សៈ កាលបើផស្សៈមិនមាន ទើបអារម្មណ៍*
*ទាំងនុ៎ះ មិនមាន អត្ថ គឺសេចក្តីវិនាស និងសេចក្តី*
*ចម្រើន ( នៃអារម្មណ៍ជាទីត្រេកអរ និងមិនជាទីត្រេក*
*អរ ) ណា អត្ថនោះ កើតមកអំពីផស្សៈនេះ តថាគត*
*សម្តែងប្រាប់ដល់អ្នក ( ដូច្នេះ ) ។*

*( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )*

ផស្សោ នុ លោកស្មិំ កុតោនិទានោ

បរិគ្គហា ចាបិ កុតោបហូតា
កិស្មឹ អសន្តេ ន មមត្តមត្ថិ
កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា។
*ចុះផស្សៈក្នុងលោក កើតមកអំពីអ្វី មួយទៀត*
*សេចក្តីហួងហែង កើតមកអំពីអ្វី កាលបើអ្វីមិនមាន*
*សេចក្តីប្រកាន់ថា របស់អញ ៗ ទើបមិនមាន កាលបើ*
*អ្វីមិនមាន ផស្សៈទាំងឡាយ ទើបមិនពាល់ត្រូវ ។*

*(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )*

នាមញ្ច រូបញ្ច បដិច្ច ផស្សោ
ឥច្ឆានិទានានិ បរិគ្គហានិ
ឥច្ឆាយសន្ត្យា ន មមត្តមត្ថិ
រូបេ វិភូតេ ន ផុសន្តិ ផស្សា។
*ផស្សៈ ( កើតឡើង ) ព្រោះអាស្រ័យនាម និងរូប*
*សេចក្តីហួងហែង កើតមកអំពីឥច្ឆា កាលបើឥច្ឆា*
*មិនមាន សេចក្តីប្រកាន់ថា របស់អញ ៗ ក៏មិនមាន*
*កាលបើរូបមិនមាន ផស្សៈទាំងឡាយ ក៏មិនពាល់ត្រូវ។*

*( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )*

កថំសមេតស្ស វិភោតិ រូបំ
សុខំ ទុខំ វាបិ កថំ វិភោតិ
ឯតំ មេ បព្រូហិ យថា វិភោតិ
តំ ជានិយាមាតិ មេ មនោ អហុ។

កាលបុគ្គលប្រតិបត្តិដូចម្តេច ទើបរូបវិនាសទៅ មួយទៀត រូបជាសុខ ( រូបគួរប្រាថ្នា ) និងរូបជាទុក្ខ ( រូបដែលមិនជាទីប្រាថ្នា ) វិនាសទៅវិញ ដោយប្រការដូចម្តេច សូមព្រះអង្គសម្តែងនូវរូបដែលជាសុខ និងជាទុក្ខនោះ ដល់ខ្ញុំ រូបដែលជាសុខ និងជាទុក្ខវិនាសទៅដោយហេតុណា ខ្ញុំដឹងនូវហេតុនោះ ខ្ញុំមានចិត្តត្រិះរិះដូច្នេះ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )

ន សញ្ញសញ្ញី ន វិសញ្ញសញ្ញី
នោបិ អសញ្ញី ន វិភូតសញ្ញី
ឯវំសមេតស្ស វិភោតិ រូបំ
សញ្ញានិទានា ហិ បបញ្ចសង្ខា ។

បុគ្គលមិនមែនជាសញ្ញាសញ្ញី បុគ្គលមិនមែនជាវិសញ្ញាសញ្ញី បុគ្គលមិនមែនជាអសញ្ញី បុគ្គលមិនមែនជាវិភូតសញ្ញី កាលបុគ្គលប្រតិបត្តិយ៉ាងនេះ រូបទើបវិនាសបាន ព្រោះធម៌ជាចំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ។

( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )

យំ តំ អបុច្ឆិម្ហ អកិត្តយី នោ
អញ្ញំ តំ បុច្ឆាម តទិង្ឃ ព្រូហិ
ឯត្តាវតគ្គំ នុ វទន្តិ ហេកេ
យក្ខស្ស សុទ្ធិំ ឥធ បណ្ឌិតាសេ

ឧទាហុ អញ្ញម្បិ វទន្តិ ឯកេ្ត។

ខ្ញុំបានសួរនូវធម៌ណា ព្រះអង្គក៏បានសម្តែងធម៌នោះ ដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសម្តែងធម៌នោះ ដល់ខ្ញុំឲ្យទាន ( បពិត្រព្រះអង្គ ) ចុះសមណព្រាហ្មណ៍ ជាបណ្ឌិតពួកខ្លះ ក្នុងលោកនេះ សម្តែងនូវសេចក្តីបរិសុទ្ធិដ៏ប្រសើរ របស់សត្វថា បំផុតត្រឹមប៉ុណ្ណោះឬ ឬក៏សម្តែងនូវ សេចក្តីបរិសុទ្ធិដទៃ ជាងអរូបសមាបត្តិនេះទៅទៀត។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )

ឯត្តាវតគ្គម្បិ វទន្តិ ហេកេ
យក្ខស្ស សុទ្ធិំ ឥធ បណ្ឌិតាសេ
តេសំ បនេកេ សមយំ វទន្តិ
អនុបាទិសេសេ កុសលា វទានា។

ពួកសមណព្រាហ្មណ៍ជាបណ្ឌិតពួកខ្លះ សម្តែងនូវ អរូបសមាបត្តិទាំងឡាយនោះ ថាជាធម៌ដ៏បរិសុទ្ធិ ប្រសើររបស់សត្វតែប៉ុណ្ណោះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះទៀត (ឧច្ឆេទវាទ ) ជាអ្នកពោលលើកខ្លួនថា ឆ្លៀវឆ្លាស ក្នុងអនុបាទិសេសនិព្វាន តែងប្រកាន់ពោលនូវលទ្ធិ គឺសេចក្តីដាច់សូន្យថា ( ជាធម៌ដ៏បរិសុទ្ធប្រសើរ របស់សត្វ ) ។

ឯតេ ច ញត្វា ឧបនិស្សិតាតិ
ញត្វា មុនី និស្សយេ សោ វិមំសី
ញត្វា វិមុត្តោ ន វិវាទមេតិ
ភវាភវាយ ន សមេតិ ធីរោតិ ។

*ព្រះពុទ្ធជាវីមំសីបណ្ឌិត ទ្រង់ជ្រាបនូវពួកសមណ-ព្រាហ្មណ៍ទាំងនោះថា ជាអ្នកអាស្រ័យនូវសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិផង ទ្រង់ជ្រាបនូវធម៌គ្រឿងអាស្រ័យនៅ ( របស់ពួកសមណព្រាហ្មណ៍ទាំងនោះ ) ផង ជ្រាប ( នូវធម៌ទាំងឡាយ ថាជាទុក្ខមិនទៀងជាដើម ) ហើយបានរួចស្រឡះផង ទើបមិនដល់នូវការទាស់ទែង អ្នកប្រាជ្ញតែងមិនមកដើម្បីកើតរឿយ ៗ ឡើយ ។*

កលហវិវាទសុត្តំ *ចប់ កលហវិវាទសូត្រ ។*

# មហាវិយូហសូត្រ[១]

## ពួកទេវតានិងមនុស្សជាមោហចរិត

## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/៣០១)

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

យេ កេចិមេ ទិដ្ឋិបរិព្វសានា
ឥទមេវ សច្ចន្តិ វិវាទយន្តិ
សព្វេវ តេ និន្ទមន្វានយន្តិ
អថោ បសំសម្បិ លភន្តិ តត្ថ ។

*សមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ ( របស់ខ្លួន) តែងជជែកគ្នាថា នេះឯងជារបស់ពិត តើពួកសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមករឿយ ៗ នូវពាក្យនិន្ទា ឬបាននូវពាក្យសរសើរ ព្រោះទិដ្ឋិរបស់ខ្លួននោះ ដែរឬ ។*

(*ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

អប្បញ្ហិ ឯតំ ន អលំ សមាយ
ទុវេ វិវាទស្ស ផលានិ ព្រូមិ
ឯតម្បិ ទិស្វា ន វិវាទយេថ
ខេមាភិបស្សំ អវិវាទភូមិំ ។

---

១ ច្បាប់ឆដ្ឋសង្គាយនាថា មហាព្យូហសូត្រ ។

*ផលនៃវាទៈ គឺសេចក្តីសរសើរនុ៎ះ មានបន្តិចបន្តួចទេ មិនគួរដើម្បីសេចក្តីស្ងប់រម្ងាប់ ( រាគៈជាដើម ) បានឡើយ តថាគតពោលនូវផលនៃការជជែកគ្នា ព្រោះទិដ្ឋិមានពីរប្រការ គឺនិន្ទា និងសរសើរ ចំណែកជនជាបណ្ឌិត ឃើញទោសក្នុងការជជែកគ្នានុ៎ះ ហើយឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនទាស់ទែងគ្នា ថាជាទីដ៏ក្សេមក្សាន្ត ទើបមិនទាស់ទែងគ្នា ។*

យា កាចិមា សម្មុតិយោ បុថុជ្ជា
សព្វាវ ឯតា ន ឧបេតិ វិទ្វា
អនូបយោ សោ ឧបយំ កិមេយ្យ ទិដ្ឋេ
សុតេ ខន្តិមកុព្វមានោ។

*ទិដ្ឋិទាំងឡាយ ឯណាមួយដែលកើតច្រើន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវទិដ្ឋិទាំងនុ៎ះ បើលោកមិនមានសេចក្តីប្រកាន់ ( នូវទិដ្ឋិ ) មិនធ្វើសេចក្តីស្រឡាញ់អារម្មណ៍ដែលឃើញហើយ ឮហើយ ធ្វើម្តេចឡើយនឹងប្រកាន់នូវអារម្មណ៍ដែលគួរប្រកាន់ ។*

សីលុត្តមា សញ្ញមេនាហុ សុទ្ធិំ
វតំ សមាទាយ ឧបដ្ឋិតាសេ
ឥធេវ សិក្ខេម អថស្ស សុទ្ធិំ
ភវូបនីតា កុសលា វទានា។

សមណព្រាហ្មណ៍ពួកមួយ ប្រកាន់ពោលថា សីលជាគុណដ៏ខ្ពង់ខ្ពស់ ហើយសម្តែងនូវសេចក្តីបរិសុទ្ធិ ដោយគុណត្រឹមតែការសង្រួម ជនទាំងឡាយនោះ សមាទាននូវវត្តហើយ ប្រកាន់មាំ ( ក្នុងវត្តដែលខ្លួនសមាទាននោះ ) ដោយគិតឃើញថា យើងទាំងឡាយ នឹងសិក្សានូវសេចក្តីបរិសុទ្ធិរបស់វត្តនោះ ក្នុងទិដ្ឋិរបស់ខ្លួននេះ តែម្យ៉ាង ព្រោះជនទាំងឡាយនោះមានភព គឺកម្មនាំចូលទៅជិតហើយ តែងពោលនូវខ្លួនថា ជាអ្នកឈ្លាស ។

សចេ ចុតោ សីលវតតោ ហោតិ
បវេធតី កម្មវិរាធយិត្វា
បជប្បតី បត្ថយតី ច សុទ្ធិំ
សត្ថាវ ហីនោ បវសំ ឃរម្ហា។

បើបុគ្គលណា ឃ្លាតចាកសីល និងវតហើយ បុគ្គលនោះ រមែងញាប់ញ័រព្រោះខុសចាកកម្ម បុគ្គលនោះឯង តែងចង់បានផង ប្រាថ្នាផង នូវសេចក្តីបរិសុទ្ធិ ដូចបុគ្គលកាលព្រាត់ប្រាសចាកផ្ទះ ហើយសាបសូន្យចាកពួក ។

សីលព្វតំ វាបិ បហាយ សព្វំ
កម្មញ្ច សាវជ្ជនវជ្ជមេតំ

សុទ្ធិំ អសុទ្ធិន្តិ អបត្ថយានោ
វិរតោ ចរេ សន្តិមនុគ្គហាយ ។

មួយទៀត អរិយសាវក លះបង់សីល និងវ័ត (ដ៏បរិសុទ្ធិ ) ទាំងអស់ផង កម្មមានទោសផង មិនមានទោសនុ៎ះផង ចេញហើយ មិនប្រាថ្នានូវសេចក្តីបរិសុទ្ធិ និងសេចក្តីមិនបរិសុទ្ធិផង ឈ្មោះថា ជាអ្នកវៀរស្រឡះ ព្រោះមិនប្រកាន់នូវទិដ្ឋិ ។

តមូបនិស្សាយ ជិគុច្ឆិតំ វា
អថវាបិ ទិដ្ឋំ វ សុតំ មុតំ វា
ឧទ្ធំសរា សុទ្ធិមនុត្ថុនន្តិ
អវីតតណ្ហាសេ ភវាភវេសុ ។

មានសមណព្រាហ្មណ៍ពួកមួយ តែងអាស្រ័យទិដ្ឋិនោះដែលគួរខ្ពើម មួយទៀត តែងអាស្រ័យទិដ្ឋិ ( សេចក្តីយល់ឃើញ ) ថា បរិសុទ្ធិព្រោះឃើញ បរិសុទ្ធិព្រោះស្តាប់ បរិសុទ្ធិព្រោះពាល់ត្រូវ ជាឧទ្ធំសរវ៉ាង ជាអ្នកមានតណ្ហាក្នុងភពតូចនិងភពធំ មិនទាន់ទៅប្រាស រមែងពោលនូវសេចក្តីបរិសុទ្ធិ ។

បត្ថយមានស្ស ហិ ជប្បិតានិ
បវេធិតំ វាបិ បកប្បិតេសុ
ចុតូបបាតោ ឥធ យស្ស នត្ថិ
ស កេន វេធេយ្យ កុហិំ វ ជប្បេ ។

ជប្បទៈ គឺតណ្ហាទាំងឡាយ ក៏កើតឡើងដល់បុគ្គល
អ្នកប្រាថ្នា ឬសេចក្ដីរន្ធត់ញាប់ញ័រ ក៏កើតឡើងក្នុង
ធម៌ទាំងឡាយ ដែលខ្លួនកំណត់ហើយ ការច្យុតិ
និងការកើតឡើង របស់បុគ្គលណា មិនមានក្នុង
លោកនេះ បុគ្គលនោះ គប្បីញាប់ញ័រដោយហេតុអ្វី
គប្បីប្រាថ្នាក្នុងអ្វីទៀត ។

( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )

យមាហុ ធម្មំ បរមន្តិ ឯកេ
តមេវ ហីនន្តិ បនាហុ អញ្ញេ
សច្ចោ នុ វាទោ កតមោ ឥមេសំ
សព្វេវ ហីមេ កុសលា វទានា ។

សមណព្រាហ្មណ៍ពួកមួយ បាននិយាយធម៌ណា
ថាជាធម៌ដ៏ឧត្ដម សមណព្រាហ្មណ៍ពួកឯទៀត បាន
និយាយធម៌នោះ ថាជាធម៌ថោកទាបវិញ ចុះពាក្យ
របស់សមណព្រាហ្មណ៍ទាំងពីរពួក តើពាក្យណា
ជាពាក្យពិតត្រង់ ព្រោះសមណព្រាហ្មណ៍ទាំងអស់
នេះ តែងពោលលើកខ្លួនថា ជាអ្នកឈ្លាស ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )

សកញ្ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ

ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មុតិមាហុ សច្ចំ ។

*សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួន ថា ជាធម៌បរិបូណ៌ ( ល្អពេញទី ) ពោលធម៌របស់ជនដទៃ ថាជាធម៌ថោកទាប សមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះ រមែងបង្កជម្លោះ ឲ្យកើតឡើង បានសរសើរទិដ្ឋិរបស់ខ្លួន ៗ ថា ជាធម៌ពិត ។*

បរស្ស ចេ វម្ភយិតេន ហីនោ
ន កោចិ ធម្មេសុ វិសេសិ អស្ស
បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ
និហីនតោ សម្ហិ ទឡ្ហំ វទានា ។

*បើបុគ្គលនោះ នឹងទៅជាអ្នកថោកទាប ព្រោះដំនៀលរបស់បុគ្គលដទៃ មិនមានអ្នកណាមួយ ដែលវិសេសក្នុងធម៌ទាំងឡាយបានទេ ព្រោះថា បុគ្គលច្រើននាក់ជាអ្នកប្រកាន់មាំក្នុងធម៌របស់ខ្លួន តែងតិះដៀលធម៌របស់ជនដទៃ ថាជាថោកទាប ។*

សទ្ធម្មបូជាបិ នេសំ តថេវ
យថា បសំសន្តិ សកាយនានិ
សព្វេវ វាទា តថិយា ភវេយ្យុំ
សុទ្ធី ហិ នេសំ បច្ចត្តមេវ ។

ជនទាំងឡាយ តែងសរសើរនូវផ្លូវជាគ្រឿងប្រព្រឹត្ត
ទៅ នៃសេចក្តីប្រតិបត្តិ គឺធម៌របស់ខ្លួន យ៉ាងណា
ការបូជាធម៌របស់ខ្លួន ក៏យ៉ាងនោះ ( កាលបើយ៉ាង
នេះ ) ពាក្យទាំងពួង គប្បីជារបស់ពិតមែន សេចក្តី
បរិសុទ្ធិនឹងមានចំពោះខ្លួននៃសមណព្រាហ្មណ៍
ទាំងនោះពិត ។

ន ព្រាហ្មណស្ស បរនេយ្យមត្ថិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា វិវាទានិ ឧបាតិវត្តោ
ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញំ។

ញាណដែលបុគ្គលដទៃគប្បីដឹកនាំ និងសេចក្តីប្រកាន់
ព្រោះវិនិច្ឆ័យក្នុងទិដ្ឋិធម៌ទាំងឡាយ មិនមានដល់
ខីណាសវព្រាហ្មណ៍ ព្រោះហេតុនោះ ខីណាសវ-
ព្រាហ្មណ៍នោះ ទើបឆ្លងពាក្យវិវាទទាំងឡាយបាន
ទាំងមិនយល់ឃើញធម៌ដទៃថា ប្រសើរទេ ។

ជានាមិ បស្សាមិ តថេវ ឯតំ
ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិំ
អទ្ទក្ខិ ចេ កិញ្ហិ តុមស្ស តេន
អតិសិត្វា អញ្ញេន វទន្តិ សុទ្ធិំ។

សមណព្រាហ្មណ៍ពួកមួយ ពោលអាងបរិសុទ្ធិ

ដោយទិដ្ឋិ ថាខ្ញុំដឹង ខ្ញុំឃើញ របស់នុ៎ះពិតមែន បើទុក
ជាមាន សមណព្រាហ្មណ៍ខ្លះ បានឃើញដោយ
បរចិត្តញ្ញាណជាដើម នឹងមានប្រយោជន៍អ្វី ដោយការ
ឃើញរបស់សមណព្រាហ្មណ៍នោះ ( បានជា ) ពួក
សមណព្រាហ្មណ៍ខ្លះ កន្លង ( នូវអរិយមគ្គ ) ហើយ
សម្តែងនូវសេចក្តីបរិសុទ្ធិ ដោយឧបាយដទៃវិញ ។

បស្សំ នរោ ទក្ខតិ នាមរូបំ
ទិស្វាន វា ញស្សតិ តានិមេវ
កាមំ ពហុំ បស្សតុ អប្បកំ វា
ន ហិ តេន សុទ្ធឹ កុសលា វទន្តិ។

នរជន កាលឃើញ រមែងឃើញតែនាមរូប លុះឃើញ
ហើយ រមែងដឹងនូវនាមរូបនោះ ប៉ុណ្ណោះ កាលបើ
ឃើញដោយវិបល្លាសសញ្ញាយ៉ាងនេះ ចង់ឃើញ
ច្រើន ឬតិចក៏ដោយ អ្នកប្រាជ្ញទាំងឡាយ មិនពោល
នូវសេចក្តីបរិសុទ្ធិដោយការឃើញត្រឹមប៉ុណ្ណោះទេ ។

និវិស្សវាទី ន ហិ សុព្វិនាយោ
បកប្បិតំ ទិដ្ឋិ បុរេក្ខរានោ
យំ និស្សិតោ តត្ថ សុភំ វទានោ
សុទ្ធិំវទោ តត្ថ តថទ្ទសា សោ។

បុគ្គលអ្នកពោលប្រកាន់មាំ មិនងាយគេប្រដៅបានទេ

បុគ្គលអ្នកធ្វើ ទិដ្ឋិដែលខ្លួនកំណត់ហើយ ឲ្យជាប្រធាន អាស្រ័យនូវសាស្តាណា រមែងជាអ្នកពោលសរសើរ ថា ល្អក្នុងសាស្តានោះ បុគ្គលនោះ ជាអ្នកពោលនូវ សេចក្តីបរិសុទ្ធិ បានឃើញថា ជាធម៌ពិត ក្នុងវាទៈ របស់សាស្តានោះ ។

ន ព្រាហ្មណោ កប្បមុបេតិ
សង្ខា ន ទិដ្ឋិសារី នបិ ញាណពន្ធុ
ញត្វា ច សោ សម្មុតិយោ បុថុជ្ជា
ឧបេក្ខតី ឧគ្គហណន្តិ មញ្ញេ។

ខីណាសវព្រាហ្មណ៍ ដឹងច្បាស់ ( នូវសង្ខារធម៌ទាំងពួង) រមែងមិនប្រកាន់នូវការកំណត់ដោយតណ្ហា និងទិដ្ឋិ ជាអ្នកមិនប្រព្រឹត្តទៅក្នុងទិដ្ឋិ ទាំងមិនមានផៅពង្ស គឺតណ្ហា និងទិដ្ឋិ ដោយមិច្ឆាញាណទេ មួយទៀត ខីណាសវព្រាហ្មណ៍នោះ បានដឹងហើយនូវទិដ្ឋិទាំងឡាយ ដែលកើតហើយ អំពីជនច្រើននាក់ ក៏ព្រងើយកន្តើយ គឺមិនប្រកាន់មាំដោយអំណាចតណ្ហានិងទិដ្ឋិ ចំណែកជនទាំងឡាយដទៃ រមែងប្រកាន់ស្អិត ។

វិស្សជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី

សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញេ។
*អ្នកប្រាជ្ញក្នុងលោកនេះ លះបង់នូវកិលេសគ្រឿង*
*ចងក្រង កាលជនទាំងឡាយ មានការទាស់ទែងកើត*
*ហើយ លោកជាអ្នកមិនប្រព្រឹត្តជាពួក កាលជនទាំង*
*ឡាយមិនស្ងប់ លោកជាអ្នកស្ងប់ លោកជាអ្នក*
*ប្រងើយកន្តើយ មិនប្រកាន់ ចំណែកជនទាំងឡាយ*
*ដទៃ រមែងប្រកាន់ស្អិត ។*
បុព្វាសវេ ហិត្វា នវេ អកុព្វំ
ន ឆន្ទគូ នោបិ និវិស្សវាទី
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតិ លោកេ អនត្តគរហី។
*ខីណាសវព្រាហ្មណ៍ លះបង់នូវអាសវៈចាស់*
*មិនធ្វើអាសវៈថ្មី ជាអ្នកមិនលុះក្នុងឆន្ទាគតិ*
*(ជាដើម ) ទាំងមិនចរចាតាមសេចក្តីប្រកាន់ស្អិត*
*ខីណាសវព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ រួចស្រឡះ*
*ចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិន*
*ជាប់នៅក្នុងលោក ។*
ស សព្វធម្មេសុ វិសេនិភូតោ
យំ កិញ្ចិ ទិដ្ឋំ វ សុតំ មុតំ វា

ស បន្នភាពោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោតិ ។
*ខីណាសវព្រាហ្មណ៍នោះ លោកជាអ្នកមិនមាន មារសេនា ក្នុងធម៌ទាំងពួង មិនមានមារសេនា ក្នុងអារម្មណ៍ណាមួយ ដែលឃើញហើយ ឮហើយ ប៉ះពាល់ហើយ ខីណាសវព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ មានភារៈដាក់ចុះហើយ រួចស្រឡះចាករាគាទិក្កិលេស មិនមានគ្រឿងកំណត់ដោយតណ្ហា និងទិដ្ឋិ មិនត្រេកអរ មិនមានកិលេសជាតិគ្រឿងប្រាថ្នាឡើយ ។*

មហាវិយូហសុត្តំ និដ្ឋិតំ *ចប់មហាវិយូហសូត្រ ។*

# ចូឡវិយូហសូត្រ[១]
## ពួកទេវតានិងមនុស្សដែលជាវិតក្កចរិត
## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/២៩៦)

*( ព្រះពុទ្ធនិម្មិតទូលសួរថា )*

សកំសកំទិដ្ឋិបរិព្វសានា
វិគ្គយ្ហ នានា កុសលា វទន្តិ
យោ ឯវំ ជានាតិ ស វេទិ ធម្មំ
ឥទំ បដិក្កោសមកេវលី សោ។

*សមណព្រាហ្មណ៍ទាំងឡាយ កាលជំអក់នៅក្នុងទិដ្ឋិ (សេចក្តីយល់ឃើញ ) របស់ខ្លួន ៗ រមែងប្រកាន់មាំ ប្តេជ្ញាថា ខ្លួនជាអ្នកឈ្លៀវឆ្លាស ( ក្នុងទិដ្ឋិនោះ ) ហើយ និយាយផ្សេង ៗ គ្នា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថា ដឹងនូវធម៌ពិត បុគ្គលណា បដិសេធធម៌នេះ បុគ្គលនោះ ឈ្មោះថា មិនមានគុណបរិបូណ៌ឡើយ ។*

ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
ពាលោ បរោ អក្កុសលោតិ ចាហុ
សច្ចោ នុ វាទោ កតមោ ឥមេសំ
សព្វេវ ហីមេ កុសលា វទានា។

---

១ ច្បាប់ឆដ្ឋសង្គាយនាថា ចូឡព្យូហសូត្រ ។

លុះសមណព្រាហ្មណ៍ទាំងឡាយប្រកាន់មាំយ៉ាងនេះ
ហើយ តែងទាស់ទែងគ្នា ទាំងពោលតិះដៀលថា
បុគ្គលដទៃ ៗ ជាបុគ្គលពាល ជាបុគ្គលមិនឈ្លាសវៃ
វាទៈរបស់សមណព្រាហ្មណ៍ទាំងឡាយនេះ បែបណា
ជាវាទៈពិត ព្រោះសមណព្រាហ្មណ៍ទាំងនេះ ជាអ្នក
ពោលលើកខ្លួនថា ឆ្លៀវឆ្លាស ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )

បរស្ស ចេ ធម្មមនានុជានំ
ពាលោមកោ ហោតិ និហីនបញ្ញោ
សព្វេវ ពាលា សុនិហីនបញ្ញា
សព្វេវិមេ ទិដ្ឋិបរិព្វសានា ។

សមណព្រាហ្មណ៍ កាលបើមិនយល់ឃើញនូវធម៌
របស់ជនដទៃ ឈ្មោះថា ជាបុគ្គលពាល ជាបុគ្គល
ថោកទាប មានប្រាជ្ញាទន់ទាប សមណព្រាហ្មណ៍
ទាំងអស់ សុទ្ធតែជាបុគ្គលពាល មានប្រាជ្ញាថោកទាប
ឈ្មោះថា សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកជំអក់
នៅក្នុងទិដ្ឋិ ។

សន្ទិដ្ឋិយា ចេវ ន វីទាតា
សំសុទ្ធបញ្ញា កុសលា មុតីមា
ន តេសំ កោចិ បរិហីនបញ្ញោ

ទិដ្ឋី ហិ តេសម្បិ តថា សមត្តា។
មួយទៀត បើសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកផូរផង់ក្នុងទិដ្ឋិរបស់ខ្លួន ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា បណ្តាសមណព្រាហ្មណ៍ទាំងនោះ រកអ្នកណាមួយ មានប្រាជ្ញាថោកទាបគ្មានទេ ព្រោះថា សមណព្រាហ្មណ៍ទាំងនោះ មានទិដ្ឋិស្មើ ៗ គ្នា ។

ន វាហមេតំ តថិយន្តិ ព្រូមិ
យមាហុ ពាលា មិថុ អញ្ញមញ្ញំ
សកំសកំទិដ្ឋិមកំសុ សច្ចំ
តស្មា ហិ ពាលោតិ បរំ ទហន្តិ។

ជនទាំងឡាយ ( អ្នកធ្វើនូវជម្លោះ ) ផ្ទឹមគ្នាជាគូ ៗ បានពោលសង្កត់សង្កិននូវគ្នានឹងគ្នាដោយពាក្យណាថា អ្នកនេះ ជាបុគ្គលពាល ដូច្នេះ តថាគត មិនបានពោលនូវពាក្យនុ៎ះថា ជាពាក្យពិតឡើយ ព្រោះថា ជនទាំងនោះ បានធ្វើនូវសេចក្តីយល់ឃើញរបស់ខ្លួន ៗ ថាជារបស់ពិត ព្រោះហេតុនោះ បានជាជនទាំងនោះផុតកម្តៅបុគ្គលដទៃដោយពាក្យថា បុគ្គលពាល ។

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

យមាហុ សច្ចំ តថិយន្តិ ឯកេ
តមាហុ អញ្ញេ តុច្ឆំ មុសាតិ
ឯវម្បិ វិគយ្ហ វិវាទយន្តិ
កស្មា ន ឯកំ សមណា វទន្តិ។

*សមណព្រាហ្មណ៍ពួកខ្លះ បានសរសើរទិដ្ឋិណាថា ជារបស់ពិតទៀងទាត់ ចំណែកសមណព្រាហ្មណ៍ពួកដទៃតិះដៀលទិដ្ឋិនោះ ថាជារបស់ទទេ កុហកវិញ លុះសមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ផ្សេង ៗ យ៉ាងនេះហើយ ក៏ទាស់ទែងគ្នា ចុះសមណព្រាហ្មណ៍ទាំងឡាយ  មិននិយាយមូលមាត់គ្នាតែបែបមួយ  តើព្រោះហេតុអ្វី ។*

( *ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

ឯកញ្ហិ សច្ចំ ន ទុតីយមត្ថិ
យស្មិំ បជា នោ វិវទេ បជានំ
នានា តេ សច្ចានិ សយំ ថុនន្តិ
តស្មា ន ឯកំ សមណា វទន្តិ។

*ព្រោះថា បុគ្គលកាលដឹងច្បាស់ក្នុងសច្ចៈណា ទើបមិនទាស់ទែងគ្នា ឯសច្ចៈនោះ មានតែមួយ មិនមែនមានពីរឡើយ ប៉ុន្តែជនទាំងឡាយ តែងសរសើរសច្ចៈ*

*របស់ខ្លួនផ្សេង ៗ គ្នា ហេតុនោះ បានជាពួកសមណ-*
*ព្រាហ្មណ៍ មិននិយាយមូលមាត់គ្នាតែបែបមួយ ។*

*( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )*

កស្មា នុ សច្ចានិ វទន្តិ នានា
បវាទិយាសេ កុសលា វទានា
សច្ចានិ សុតានិ ពហូនិ នានា
ឧទាហុ តេ តក្កមនុស្សរន្តិ។

*ព្រោះហេតុអ្វីហ្ន៎ បានជាសមណព្រាហ្មណ៍ទាំងឡាយ*
*ដែលពោលលើកខ្លួនថា ជាអ្នកឆ្លៀវឆ្លាស ជាអ្នក*
*ពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេង ៗ*
*គ្នា ចុះសមណព្រាហ្មណ៍ទាំងនោះ បានឮមកថា សច្ចៈ*
*មានច្រើនផ្សេង ៗ គ្នាឬ ឬក៏សមណព្រាហ្មណ៍*
*ទាំងនោះ នឹករកដោយសេចក្ដីត្រិះរិះរបស់ខ្លួនទេ ។*

*(ព្រះមានព្រះភាគទ្រង់ត្រាស់ថា )*

ន ហេវ សច្ចានិ ពហូនិ នានា
អញ្ញត្រ សញ្ញាយ និច្ចានិ លោកេ
តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតិ ទ្វយធម្មមាហុ។

*សច្ចៈទាំងឡាយច្រើន ផ្សេង ៗ គ្នា ក្នុងលោកមិនមាន*
*ទេ លើកលែងតែសេចក្ដីប្រកាន់ថា ទៀងដោយ*

*សញ្ញាចេញ គឺមានតែបរមត្ថសច្ចៈមួយប៉ុណ្ណោះ មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ កំណត់ទុកនូវសេចក្តីត្រិះរិះ ឲ្យប្រជុំចុះក្នុងទិដ្ឋិទាំងឡាយហើយ និយាយនូវហេតុមួយគូជាធម្មតា គឺសេចក្តីពិត ១ មុសា ១ ។*

ទិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានទស្សី
វិនិច្ឆយេ ឋត្វា បហស្សមានោ
ពាលោ បរោ អក្កុសលោតិ ចាហ ។

*បុគ្គលពួកមួយ អាស្រ័យនូវទិដ្ឋិធម៌ទាំងនេះ គឺ អារម្មណ៍ដែលខ្លួន ឃើញហើយ ឬឮហើយ ដែលខ្លួនពាល់ត្រូវហើយ ឬសីលវ័ត ជាអ្នកឃើញនូវសេចក្តីប្រកាន់ធំ គឺសន្តិភាព លុះស្ថិតនៅក្នុងវិនិច្ឆ័យធម៌ គឺទិដ្ឋិ ៦២ ហើយរីករាយក៏ពោលតិះដៀលថា បុគ្គលដទៃជាបុគ្គលពោលមិនធ្លៀវធ្លាស ។*

យេនេវ ពាលោតិ បរំ ទហាតិ
តេនាតុមានំ កុសលោតិ ចាហ
សយមត្តនា សោ កុសលោ វទានោ
អញ្ញំ វិមានេតិ តទេវ ចាវ ។

*មួយទៀតបុគ្គលនោះ តែងដុតកម្តៅបុគ្គលដទៃថា ជា*

*បុគ្គលពាល ៗ ដូច្នេះ ដោយហេតុណា ក៏បានពោល លើកខ្លួនឯង ថាជាអ្នកឆ្លៀវឆ្លាស ដោយហេតុនោះ បុគ្គលនោះ ពោលលើកខ្លួនឯងថា ជាអ្នកឆ្លៀវឆ្លាស ចំពោះខ្លួនដោយខ្លួនឯង រមែងតិះដៀលបុគ្គលដទៃ ហើយពោលប្រកាន់ទិដ្ឋិនោះ ។*

អតិសារទិដ្ឋិយាវ សោ សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាភិសិត្តោ
ទិដ្ឋី ហិ សា តស្ស តថា សមត្តា។

*បុគ្គលនោះ បរិបូណ៌ហើយដោយទិដ្ឋិ គឺការយល់ឃើញថា មានខ្លឹមសារក្រៃពេក និងដោយមានៈ មានមានៈដ៏បរិបូណ៌ ប្រស់ព្រំសន្តានខ្លួនដោយមានៈ គឺប្រកាន់ថា ខ្លួនជាបណ្ឌិត ទិដ្ឋិនោះ របស់បុគ្គលនោះ បរិបូណ៌ហើយដោយប្រការដូច្នោះ ។*

បរស្ស ចេ ហិ វចសា និហីនោ
តុមោ សហា ហោតិ និហីនបញ្ញោ
អថ ចេ សយំ វេទគូ ហោតិ ធីរោ
ន កោចិ ពាលោ សមណេសុ អត្ថិ។

*ប្រសិនបើមានបុគ្គលអ្នកថោកទាប ដោយសារវាចាពាក្យតិះដៀលរបស់បុគ្គលដទៃ បុគ្គលដែលតិះដៀល*

គេនោះ នឹងទៅជាបុគ្គលមានប្រាជ្ញាថោកទាប ស្មើនឹងបុគ្គលថោកទាបនោះ មួយទៀត បើបុគ្គលនោះ ជាអ្នកដល់នូវវេទ ជាអ្នកប្រាជ្ញ មានប្រាជ្ញាខ្ជាប់ខ្ជួនចំពោះខ្លួនឯង ក៏រកបុគ្គលណាមួយ ជាមនុស្សល្ងង់ ក្នុងពួកសមណៈមិនមាន ។

អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ
អបរទ្ធា សុទ្ធិមកេវលី តេ
ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ
សន្ទិដ្ឋិរាគេន ហិ តេភិរត្តា ។

ពួកបុគ្គលណា សរសើរធម៌ គឺទិដ្ឋិដទៃក្រៅពីនេះ ពួកបុគ្គលនោះ ជាអ្នកមានគុណមិនបរិបូណ៌ ឈ្មោះថាប្រទូស្តចំពោះផ្លូវដ៏បរិសុទ្ធ ពួកតិរ្ថិយតែងនិយាយតិះដៀលគ្នា ដោយច្រើនយ៉ាងនេះឯង ព្រោះថា តិរ្ថិយទាំងនោះ ត្រេកអរស៊ប់ហើយដោយតម្រេក ក្នុងទិដ្ឋិរបស់ខ្លួន ។

ឥធេវ សុទ្ធិំ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា
សកាយនេ តត្ថ ទឡ្ហំ វទានា ។

លុះពួកតិរ្ថិយ ( ត្រេកអរយ៉ាងនេះហើយ ) ទើបនាំគ្នា

*និយាយសរសើរសេចក្ដីបរិសុទ្ធិក្នុងធម៌ ( របស់ខ្លួន ) នេះតែម្យ៉ាង មិននិយាយសរសើរសេចក្ដីបរិសុទ្ធិ ក្នុងធម៌ទាំងឡាយដទៃឡើយ ពួកតិរ្ថិយ តែងចូលចិត្តដោយច្រើនយ៉ាងនេះ ហើយពោលប្រកាន់មាំ ក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួននោះ ។*

សកាយនេ វាបិ ទឡ្ហំ វទានោ
កមេត្ថ ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគមាវហេយ្យ
បរំ វទំ ពាលមសុទ្ធិធម្មំ។

*មិនត្រឹមតែប៉ុណ្ណោះឡើយ ពួកតិរ្ថិយទាំងនោះ សូម្បីតែមួយនាក់ កាលពោលប្រកាន់មាំក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួនហើយ មុខជាដុតកម្ដៅបុគ្គលដទៃ ថាជាមនុស្សពាល ព្រោះទិដ្ឋិរបស់ខ្លួនដូច្នេះ លុះតិរ្ថិយពោលនូវបុគ្គលដទៃថា ជាមនុស្សពាល ថាជាអ្នកមានធម៌មិនបរិសុទ្ធិហើយ គប្បីនាំមកនូវជម្លោះចំពោះខ្លួនឯង ។*

វិនិច្ឆយេ ឋត្វា សយំ បមាយ
ឧទ្ធំ ស លោកស្មឹ វិវាទមេតិ
ហិត្វាន សព្វានិ វិនិច្ឆយានិ
ន មេធគំ កុព្វតិ ជន្តុ លោកេតិ។

តិរិយនោះ តាំងនៅក្នុងវិនិច្ឆយធម៌ ( ដោយតណ្ហា និងទិដ្ឋិ ) តាំងលទ្ធិដោយខ្លួនឯងហើយ រមែងដល់នូវការទាស់ទែងគ្នា ដ៏ក្រៃលែងលើសលុប ក្នុងលោក ចំណែកសត្វ ដែលលះបង់នូវវិនិច្ឆយធម៌ទាំងអស់ ( ដោយអរិយមគ្គ ) រមែងមិនធ្វើនូវជម្លោះក្នុងលោក ឡើយ ។

ចូឡវិយូហសុត្តំ និដ្ឋិតំ។ ចប់ ចូឡវិយូហសូត្រ ។

# តុវដកសូត្រ
## ពួកទេវតានិងមនុស្សដែលជាសទ្ធាចរិត
## (ខុទ្ទកនិកាយ សុត្តនិបាត ៥៨/៣០៧)

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

បុច្ឆាមិ តំ អាទិច្ចពន្ធុំ
វិវេកំ សន្តិបទញ្ច មហេសិ
កថំ ទិស្វា និព្វាតិ ភិក្ខុ
អនុបាទិយានោ លោកស្មិំ កិញ្ចិ។

*ខ្ញុំសូមសួរនូវសេចក្តីស្ងាត់ផង នូវចំណែកនៃសេចក្តីស្ងប់ផង នឹងព្រះអង្គ ជាផៅពង្សដ៏ប្រសើរ អ្នកស្វែងរកគុណដ៏ធំ ចុះភិក្ខុឃើញដោយប្រការដូចម្តេច មិនប្រកាន់មាំនូវអ្វីមួយក្នុងលោក ទើបរំលត់កិលេសបាន ។*

( *ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

មូលំ បបញ្ចសង្ខាយ
មន្តា អស្មីតិ សព្វមុបរុន្ធេ
យា កាចិ តណ្ហា អជ្ឈត្តំ
តាសំ វិនយា សទា សតោ សិក្ខេ។

*ភិក្ខុគប្បីបិទនូវឫសនៃបបញ្ចសង្ខារ ( ធម៌ជាគ្រឿងធ្វើសត្វឲ្យយឺតយូរ គឺតណ្ហា ទិដ្ឋិ )ផង នូវអស្មិមានះ*

ទាំងពួងផង ដោយប្រាជ្ញា តណ្ហាទាំងឡាយណាមួយ
មានខាងក្នុងសន្តានសត្វ ភិក្ខុជាអ្នកមានសតិ
គ្រប់ពេល គប្បីសិក្សាដើម្បីកម្ចាត់បង់តណ្ហាទាំងនោះ
ចេញ ។

យំ កិញ្ចិ ធម្មមភិជញ្ញា
អជ្ឈត្តំ អថវាបិ ពហិទ្ធា
ន តេន ថាមំ កុព្វេថ
ន ហិ សា និព្វុតិ សតំ វុត្តា។

ភិក្ខុគប្បីដឹងនូវគុណធម៌ណាមួយ ជាខាងក្នុង ឬ
ខាងក្រៅ មិនគប្បីធ្វើនូវកម្លាំង ( ការលើកតម្កើង )
ដោយគុណធម៌នោះ ព្រោះការរំលត់នោះ សប្បុរស
ទាំងឡាយ មិនបានប្រកាសឡើយ ។

សេយ្យោ ន តេន មញ្ញេយ្យ
នីចេយ្យោ អថវាបិ សរិក្ខោ
ផុដ្ឋោ អនេករូបេហិ
នាតុមានំ វិកប្បយំ តិដ្ឋេ។

ភិក្ខុមិនគប្បីសម្គាល់ថា អញជាបុគ្គលប្រសើរជាងគេ
អញជាបុគ្គលថោកទាបជាងគេ ឬថាជាបុគ្គលស្មើ ៗ
នឹងគេ ដោយសារគុណធម៌នោះឡើយ ភិក្ខុប្រកប
ដោយគុណធម៌ មានសភាពច្រើនយ៉ាង មិនគប្បី

តាំងខ្លួន តម្កើងខ្លួនទេ ។
អជ្ឈត្តមេវុបសមេ
ន អញ្ញតោ ភិក្ខុ សន្តិមេសេយ្យ
អជ្ឈត្តំ ឧបសន្តស្ស
នត្ថិ អត្តា កុតោ និរត្តា វា។
ភិក្ខុគប្បីរម្ងាប់ ( រាគាទិក្កិលេស ) ក្នុងសន្តាន ភិក្ខុមិនគប្បីស្វែងរកសេចក្តីស្ងប់ ដោយឧបាយដទៃទេ កាលបើលោករម្ងាប់នូវរាគាទិក្កិលេស ក្នុងសន្តានហើយ សេចក្តីយល់ឃើញថា ខ្លួនគឺសស្សតទិដ្ឋិរមែងមិនមាន សេចក្តីយល់ឃើញថា មិនមែនខ្លួនគឺឧច្ឆេទទិដ្ឋិ នឹងមានមកអំពីណា ។
មជ្ឈេ យថា សមុទ្ទស្ស
ឩមិ នោ ជាយតី ឋិតោ ហោតិ
ឯវំ ឋិតោ អនេជស្ស
ឧស្សទំ ភិក្ខុ នករេយ្យ កុហិញ្ចិ។
រលករមែងមិនកើតឡើងត្រង់ជម្រៅពាក់កណ្តាលសមុទ្ទ ទឹកត្រង់កណ្តាលនោះ រមែងតាំងនៅនឹង មានឧបមាយ៉ាងណាមិញ មានឧបមេយ្យ ដូចភិក្ខុអ្នកតាំងនៅនឹងនួន ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រដូច្នោះឯង មិនគប្បីធ្វើកិលេសឲ្យពុះពោរក្នុងទីណាមួយ ។

( ព្រះពុទ្ធនិម្មិតទ្រង់សួរថា )

អកិត្តយី វិវដចក្ខុ
សក្ខិធម្មំ បរិស្សយវិនយំ
បដិបទំ វទេហិ ភទ្ទន្តេ
ចាតិមោក្ខំ អថវាបិ សមាធិំ។

ព្រះអង្គមានចក្ខុបើកហើយ បានសម្ដែងធម៌ ចំពោះភ្នែក គឺធម៌ ដែលព្រះអង្គឃើញច្បាស់ហើយ ដោយព្រះអង្គឯង ជាធម៌កម្ចាត់នូវសេចក្ដីអន្តរាយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្ដែងនូវបដិបទាផង នូវបាតិមោក្ខសីលផង នូវសមាធិចិត្តផង ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា )

ចក្ខូហិ នេវ លោលស្ស
គាមកថាយ អាវរយេ សោតំ
រសេ ច នានុគិជ្ឈេយ្យ
ន ច មមាយេថ កិញ្ចិ លោកស្មិំ។

ភិក្ខុគប្បីជាអ្នកមិនរឡេមរឡាមដោយចក្ខុទាំងឡាយផង គប្បីបិទខ្ទប់នូវត្រចៀក ក្នុងពាក្យនៃអ្នកស្រុកផង មិនគប្បីជាប់នៅក្នុងរសផង មិនគប្បីប្រកាន់នូវរបស់ណាមួយក្នុងលោកផង ។

ផស្សេន យទា ផុដ្ឋស្ស

បរិទេវំ ភិក្ខុ ន ករេយ្យ
កុហិញ្ច ភវញ្ច នាភិជប្បេយ្យ
ភេរវេសុ ច ន សម្បវេធេយ្យ។

*កាលណាភិក្ខុត្រូវផស្សៈប៉ះពាល់ហើយ ភិក្ខុមិនគប្បីធ្វើនូវសេចក្ដីខ្សឹកខ្សួលផង មិនគប្បីប្រាថ្នានូវភពណាមួយផង មិនគប្បីញាប់ញ័រក្នុងសត្វសាហាវ ដែលគួរស្ញប់ស្ញែងផង ។*

អន្នានមថោ បានានំ
ខាទនីយានំ អថោបិ វត្ថានំ
លទ្ធា ន សន្និធឹ កយិរា
ន ច បរិត្តសេ តានិ អលភមានោ។

*មួយទៀត ភិក្ខុបើបាននូវបាយ ទឹក ខាទនីយៈ ឬសំពត់ទាំងឡាយហើយ មិនគប្បីធ្វើនូវសន្និធិ ( ការសន្សំទុក ) ឡើយ កាលបើមិនបានវត្ថុទាំងនោះទេ ក៏មិនគប្បីអន្ទះសារ ។*

ឈាយី ន បាទលោលស្ស
វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ
អថាសនេសុ សយនេសុ
អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យ។

*ភិក្ខុគប្បីជាអ្នកអភិរម្យក្នុងឈាន គប្បីជាអ្នកមិន*

*រពឹសដើង គប្បីវៀរចាកសេចក្ដីរពឹស ( មានរពឹស ដៃជាដើម ) មិនគប្បីធ្វេសប្រហែស មួយទៀត គប្បី នៅក្នុងទីអង្គុយ ទីដេក ដែលមានសំឡេងតិច ។*

និទ្ទំ ន ពហុលីករេយ្យ
ជាគរិយំ ភជេយ្យ អាតាបី
តន្ទិំ មាយំ ហស្សំ ខិឌ្ឌំ
មេថុនំ វិប្បជហេ សវិភូសំ។

*ភិក្ខុមានសេចក្ដីព្យាយាម មិនគប្បីធ្វើការដេកលក់ឲ្យ ច្រើនទេ គប្បីគប់រកនូវសេចក្ដីភ្ញាក់រឭក គប្បីលះបង់ សេចក្ដីខ្ជិលច្រអូស មាយា ល្បែងសើច ល្បែងលេង មេថុន ព្រមទាំងការស្អិតស្អាងខ្លួនចេញ ។*

អាថព្វណំ សុបិនំ លក្ខណំ
នោ វិទហេ អថោបិ នក្ខត្តំ
វិរុតញ្ច គព្ភករណំ
តិកិច្ឆំ មាមកោ ន សេវេយ្យ។

*ភិក្ខុអ្នករាប់អានព្រះរតនត្រ័យ មិនគប្បីប្រកប អាថព្វណមន្ត ( មន្តសម្រាប់ឲ្យឧបទ្រវៈកើតឡើង ក្នុងបច្ចាមិត្ត ) មន្តសម្រាប់ទាយសុបិន មន្តសម្រាប់ ទាយលក្ខណៈ មន្តសម្រាប់សម្ដែងឫក្សមង្គល មិន គប្បីសេពគប់មន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំ*

*សម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង ។*

និន្ទាយ នប្បវេធេយ្យ

ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខុ

លោភំ សហ មច្ឆរិយេន

កោធំ បេសុណិយញ្ច បនុទេយ្យ។

*ភិក្ខុមិន គប្បីញាប់ញ័រនឹងពាក្យនិន្ទា បើមានគេសរសើរ ក៏មិនគប្បីឡើងជោរផង គប្បីបន្ទោបង់លោភៈ មច្ឆរិយៈ សេចក្តីក្រេវក្រោធនិងពាក្យញុះញង់ ។*

កយវិក្កយេ ន តិដ្ឋេយ្យ

ឧបវាទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ

គាមេ ច នាភិសជ្ជេយ្យ

លាភកម្យា ជនំ ន លបយេយ្យ។

*ភិក្ខុមិនគប្បីតាំងនៅក្នុងការលក់ចេញ ទិញចូល មិនគប្បីធ្វើការពោលតិះដៀលក្នុងទីណាមួយ មិនគប្បីជាប់ចិត្តក្នុងស្រុក មិនគប្បីចរចានឹងជន ព្រោះប្រាថ្នាលាភ ។*

ន ច កត្ថិតា សិយា ភិក្ខុ

ន ច វាចំ បយុត្តំ ភាសេយ្យ

ចាគព្ភិយំ ន សិក្ខេយ្យ

កថំ វិគ្គាហិកំ ន កថយេយ្យ។
មួយទៀត ភិក្ខុមិនគប្បីពោលវាចាលើកខ្លួន មិនគប្បីពោលវាចាផ្សេងៗ មិនគប្បីសិក្សានូវសេចក្ដីឃ្លើសឃ្លង កាយវាចាចិត្ត មិនគប្បីពោលពាក្យប្រណាំប្រជែង ។

មោសវជ្ជេ ន និយេថ
សម្បជានោ សឋានិ ន កយិរា
អថ ជីវិតេន បញ្ញាយ
សីលព្វតេន នាញ្ញមតិមញ្ញេ។

ភិក្ខុមិនគប្បីដឹកនាំ ក្នុងពាក្យមុសាវាទ មិនគប្បីធ្វើការអួតអាងទាំងដឹងខ្លួន មួយទៀត មិនគប្បីមើលងាយអ្នកដទៃ ដោយអាជីវៈ ( ការចិញ្ចឹមជីវិត ) និងបញ្ញា និងសីលវ័ត ។

សុត្វា រុសិតោ ពហុំ វាចំ
សមណានំ វា បុថុជនានំ
ផរុសេន នេ ន បដិវជ្ជា
ន ហិ សន្តោ បដិសេនិករោន្តិ។

ភិក្ខុកាលបើបានឮពាក្យ( មិនជាទីគាប់ចិត្ត ) ដ៏ច្រើន របស់សមណៈទាំងឡាយ ឬរបស់បុថុជ្ជនទាំងឡាយ មិនគប្បីប្រទូស្តទៅរក មិនគប្បីពោលតប ដោយពាក្យអាក្រក់ ព្រោះថា លោកអ្នកស្ងប់រម្ងាប់

ទាំងឡាយ រមែងមិនធ្វើការឈ្លោះតបតឡើយ ។

ឯតញ្ច ធម្មមញ្ញាយ

វិចិនំ ភិក្ខុ សទា សតោ សិក្ខេ

សន្តីតិ និព្ពុតឹ ញត្វា

សាសនេ គោតមស្ស ន បមជ្ជេយ្យ។

ភិក្ខុកាលបានដឹង បានពិចារណាធម៌នុ៎ះ គប្បីជាអ្នករឭកសិក្សាសព្វកាល បើបានដឹងសេចក្ដីរំលត់រាគាទិក្កិលេស ថាជាសេចក្ដីស្ងប់ហើយ មិនគប្បីប្រហែសធ្វេស ក្នុងសាសនានៃព្រះគោតមឡើយ ។

អភិភូ ហិ សោ អនភិភូតោ

សក្ខិធម្មមនីតិហាមទស្សី

តស្មា ហិ តស្ស ភគវតោ សាសនេ

អប្បមត្តោ សទា នមស្សមនុសិក្ខេតិ។

ភិក្ខុនោះ ជាអ្នកគ្របសង្កត់រូបជាដើម ជាអ្នកដែលរូបជាដើម គ្របសង្កត់មិនបាន ជាអ្នកឃើញធម៌ ចំពោះភ្នែកឯង មិនអាងគេថា ដូច្នេះ ៗ ព្រោះហេតុនោះ ភិក្ខុគប្បីជាអ្នកមិនប្រហែស គប្បីនមស្ការសិក្សាក្នុងសាសនានៃព្រះមានព្រះភាគនោះ សព្វ ៗ កាល ។

តុវដកសុត្តំ និដ្ឋិតំ។ ចប់ តុវដកសូត្រ ។

# បុរាភេទសូត្រ

## ពួកទេវតានិងមនុស្សដែលជាពុទ្ធចរិត

## (ខុទ្ទកនិកាយ សុត្តនិបាត ៥៤/២៨៧)

( *ព្រះពុទ្ធនិម្មិតទ្រង់សួរថា* )

កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតិ
តំ មេ គោតម បព្រូហិ បុច្ឆិតោ ឧត្តមំ នរំ។

*បុគ្គលអ្នកមានទស្សនៈដូចម្តេច មានសីលដូចម្តេច ដែលព្រះអង្គត្រាស់ហៅថា អ្នកស្ងប់រម្ងាប់ បពិត្រព្រះគោតម ព្រះអង្គ ដែលខ្ញុំសួរហើយ សូមប្រាប់នូវឧត្តមជននោះ ។*

( *ព្រះមានព្រះភាគទ្រង់ត្រាស់ថា* )

វីតតណ្ហោ បុរា ភេទា បុព្វមន្តមនិស្សិតោ
វេមជ្ឈេ នុបសង្ខេយ្យោ តស្ស នត្ថិ បុរក្ខតំ។

*មុននឹងបែកធ្លាយរាងកាយទៅ បុគ្គលណា ប្រាសចាកតណ្ហា មិនអាស្រ័យនូវកាលខាងដើម និងទីបំផុត គឺកាលជាអតីតៈ និងអនាគត ជាបុគ្គលដែលអ្នកប្រាជ្ញ មិនគប្បីពោលថា ជាអ្នកត្រេកអរ ក្នុងបច្ចុប្បន្ន ការធ្វើនូវតណ្ហា និងទិដ្ឋិឲ្យជាប្រធាននៃបុគ្គលនោះ មិនមានឡើយ ។*

អក្កោធនោ អសន្តាសី អវិកត្ថី អកុក្កុចោ
មន្តភាណី អនុទ្ធតោ ស វេ វាចាយតោ មុនិ។

*បុគ្គលនោះឯង មិនក្រោធ មិនតក់ស្លុត មិនពោលអួត*

មិនរពឹស ជាអ្នកពោលដោយបញ្ញា មិនរាយមាយ សង្រួមដោយវាចា ជាអ្នកប្រាជ្ញ ។

និរាសត្តិ អនាគតេ　　អតីតំ នានុសោចតិ
វិវេកទស្សី ផស្សេសុ　　ទិដ្ឋីសុ ច ន នីយតិ ។

បុគ្គលមិនមានតណ្ហាក្នុងអារម្មណ៍ជាអនាគត មិនសោកស្តាយនូវអារម្មណ៍អតីតៈ ជាអ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ មិនបង្អោនចិត្ត ទៅក្នុងមិច្ឆាទិដ្ឋិទាំងឡាយ ។

បតិលីនោ អកុហកោ　　អបិហាលុ អមច្ឆរី
អប្បគព្ភោ អជេគុច្ឆោ　　បេសុណេយ្យេ ច នោ យុតោ ។

ជាអ្នកពួនសម្ងំ មិនបំភាន់គេ មិនមានសេចក្តីប្រាថ្នាជាប្រក្រតី មិនមានសេចក្តីកំណាញ់ មិនឃ្នើសឃ្នង ជាបុគ្គលដែលគេមិនស្អប់ខ្ពើម ជាអ្នកមិនប្រកបក្នុងការញុះញង់ ។

សាតិយេសុ អនស្សាវី　　អតិមានេ ច នោ យុតោ
សណ្ហោ ច បដិភាណវា　　ន សទ្ធោ ន វិរជ្ជតិ ។

មិនទឹកនាទៅរកវត្ថុជាទីត្រេកអរ មិនប្រកបក្នុងការមើលងាយគេ ជាអ្នកមានការងាររល្អិតល្អ មានបដិភាណ មិនជឿអ្នកដទៃ ។

លាភកម្យា ន សិក្ខតិ　　អលាភេ ច ន កុប្បតិ
អវិរុទ្ធោ ច តណ្ហាយ　　រសេសុ នានុគិជ្ឈតិ ។

*មិនត្រេកអរ មិនសិក្សា ព្រោះប្រាថ្នាលាភ មិនក្រេវក្រោធ ព្រោះមិនមានលាភ ជាអ្នកមិនខឹង មិនជាប់ចិត្តក្នុងរស ព្រោះតណ្ហា ។*

ឧបេក្ខកោ សទា សតោ ន លោកេ មញ្ញតេ សមំ
ន វិសេសី ន នីចេយ្យោ តស្ស នោ សន្តិ ឧស្សទា ។

*ជាបុគ្គលមានឧបេក្ខា មានសតិសព្វពេល មិនសម្គាល់ថាស្មើនឹងគេក្នុងលោក មិនលើកខ្លួនថា វិសេសជាងគេ មិនដាក់ខ្លួនថា ថោកទាបជាងគេ កិលេសគ្រឿងពុះពោរ មិនមានដល់បុគ្គលនោះឡើយ ។*

យស្ស និស្សយនា នត្ថិ ញត្វា ធម្មំ អនិស្សិតោ
ភវាយ វិភវាយ វា តណ្ហា យស្ស ន វិជ្ជតិ ។

*បុគ្គលណា មិនមាននិស្សយធម៌ គឺតណ្ហា និងទិដ្ឋិក្តី បុគ្គលណាដឹងនូវធម៌ ហើយមិនអាស្រ័យនូវតណ្ហា និងទិដ្ឋិក្តី បុគ្គលមិនមានតណ្ហាក្នុងសេចក្តីចម្រើន និងសេចក្តីវិនាស ។*

តំ ព្រូមិ ឧបសន្តោតិ កាមេសុ អនបេក្ខិនំ
គន្ថា តស្ស ន វិជ្ជន្តិ អតរី សោ វិសត្តិកំ ។

*តថាគតហៅបុគ្គលអ្នកមិនអាឡោះអាល័យក្នុងកាមទាំងឡាយនោះថា ជាអ្នកស្ងប់រម្ងាប់ កិលេសគ្រឿងចាក់ស្រែះរបស់បុគ្គលនោះ មិនមាន បុគ្គលនោះ បានឆ្លងនូវតណ្ហាដែលផ្សាយទៅហើយ ។*

ន តស្ស បុត្តា បសវោ　　ខេត្តំ វត្ថុញ្ច វិជ្ជតិ
អត្តា វាបិ និរត្តា វា　　ន តស្មឹ ឧបលព្ភតិ ។

*កូនទាំងឡាយ សត្វចិញ្ចឹមទាំងឡាយ និងស្រែចម្ការ ទីលំនៅរបស់បុគ្គលនោះ មិនមានឡើយ សេចក្តីប្រកាន់ថា ជារបស់ខ្លួន គឺសស្សតទិដ្ឋិក្តី សេចក្តីប្រកាន់ថា មិនមែនជារបស់ខ្លួន គឺឧច្ឆេទទិដ្ឋិក្តី មិនមានក្នុងបុគ្គលនោះទេ ។*

យេន នំ វជ្ជុំ បុថុជ្ជនា　　អថោ សមណព្រាហ្មណា
តំ តស្ស អបុរក្ខតំ　　តស្មា វាទេសុ នេជតិ ។

*ពួកទេវតា និងមនុស្ស ជាបុថុជ្ជន ឬពួកសមណព្រាហ្មណ៍ គប្បីពោលទោសចំពោះបុគ្គលនោះ ដោយកិលេសមានរាគៈជាដើមណា កិលេសមានរាគៈជាដើមនោះ បុគ្គលនោះមិនធ្វើឲ្យជាប្រធានឡើយ ព្រោះហេតុនោះបុគ្គលមិនញាប់ញ័រ ព្រោះពាក្យពោលទាំងឡាយឡើយ ។*

វីតគេធោ អមច្ឆរី　　ន ឧស្សេសុ វទតេ មុនិ
ន សមេសុ ន ឱមេសុ　　កប្បំ នេតិ អកប្បិយោ ។

*អ្នកប្រាជ្ញប្រាសចាកសេចក្តីជាប់ជំពាក់ ( ក្នុងរូបជាដើម ) មិនមានសេចក្តីកំណាញ់ មិននិយាយលើកខ្លួន ក្នុងគុណដ៏ខ្ពង់ខ្ពស់ មិននិយាយប្រកបខ្លួន ក្នុងគុណដ៏ស្មើ ៗ មិននិយាយបន្ទាបខ្លួន ក្នុងគុណដ៏ថោកទាប មិនដល់នូវកប្បៈ គឺមិនមានតណ្ហានិងទិដ្ឋិ ព្រោះជាបុគ្គលមិនមានកប្បៈ ។*

យស្ស លោកេ សកំ នត្ថិ អសតា ច ន សោចតិ
ធម្មេសុ ច ន គច្ឆតិ ស វេ សន្តោតិ វុច្ចតីតិ។

*បុគ្គលណា មិនមានសេចក្តីប្រកាន់ថា របស់ខ្លួនក្នុងលោក បុគ្គលនោះ មិនសោកព្រោះរបស់ដែលមិនមាន មិនលុះក្នុងអគតិធម៌ទាំងឡាយ បុគ្គលនោះឯង ហៅថា អ្នកស្ងប់រម្ងាប់ ។*

បុរាភេទសុត្តំ និដ្ឋិតំ។ *ចប់ បុរាភេទសូត្រ ។*

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~